

# ប្រវត្តិដំណាំកៅស៊ូនៅកម្ពុជា



# ប្រវត្តិដំណាំកៅស៊ូ

## ប្រវត្តិរបស់មនុស្ស និងរបរចេះកទេស


បុព្វកថា ........ ៤

គនិទាមកសិករដាំកៅស៊ូតូចតាច ........ ៦

កម្ពុជា ទឹកដីនៃដំណាំកៅស៊ូ ........ ៩

សព្ទានុក្រម ........ ៤២

ដើមកៅស៊ូ ជ័រ និងផលិតផលកៅស៊ូ ........ ៦១

ចំការដំណាំកៅស៊ូគ្រួសារ ........ ៦៦

កសិករដាំកៅស៊ូតូចតាច ........ ៧៧

ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៥០ វេលាម៉ោង ១៤:០០

ថ្ងៃមួយ នៅដើមរដូវភ្លៀង នៅពេលដែលអាកាសយានស្លាបលើមួយជាន់ ឈ្មោះ Stinson បានដាក់រូបខ្ញុំនៅលើទីវាលចំការជុប ។ ទីនេះគឺជាលំនៅដ្ឋានថ្មីរបស់ខ្ញុំសម្រាប់រយៈពេលបីឆ្នាំ នៅព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីបានធ្វើការនៅចំការកៅស៊ូតាមដាំង និងក្រោយមកនៅចំការកៅស៊ូជុប ។

ការប្រយុទ្ធគ្នានៅជាប់ព្រំដែនប្រទេសវៀតណាមបាននាំមកនូវបញ្ហាអសន្តិសុខ និងធ្វើឱ្យស្មុគស្មាញដល់ការដាំដុះកៅស៊ូឡើងវិញ: "កៅស៊ូដាំដោយគ្រាប់" កាលពីជំនាន់ខ្ញុំ បើគិតពីផ្នែកសោភ័ណភាព នៅតែជាស្តេចនៃ "ឫកកៅស៊ូ" ដដែល ហើយបានបន្តរហូតដល់ជាង៤០ឆ្នាំ ។

ការខិតជិតដល់ឯករាជ្យបានបង្ខំឱ្យអគ្គនាយកដ្ឋានត្រៀមកម្មករខ្មែរដើម្បីជំនួសកម្លាំងពលកម្មវៀតណាម: សាលាបង្រៀនទៀរជ័រលើកដំបូងត្រូវបានបង្កើតឡើង ការជ្រើសរើសកម្មករមានការលំបាក ពីព្រោះ "ប្រជាជនខ្មែរកូចកាច" តាមព្រះរាជបន្ទូលរបស់ព្រះមហាក្សត្របានបញ្ជាក់អំពីភាពមិនយល់ដឹងយ៉ាងហោចណាស់អំពីភាពញញើតញញើមចំពោះ "ឧស្សាហកម្ម" មួយ ដែលខុសគ្នាពីការងារពីបុព្វបុរសដើម ។

ដូច្នេះ តើមានទំនាក់ទំនងអ្វីខ្លះរវាងដីក្រហមបាសាល់ និងដីស្រែ? ជាភ័ព្វសំណាងនៅជំនាន់នោះ ជុបបានជ្រើសរើសមន្ត្រីកម្ពុជាពីររូប គឺលោកតូច សៅ ឱ្យទទួលខុសត្រូវខាងដឹកជញ្ជូន ។ គាត់គឺជាវីរបុរសម្នាក់នៅក្នុងសង្គ្រាមទីមួយជាមួយសៀមកាលពីឆ្នាំ១៩៤១ ហើយបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម ។ ចំណែកមន្ត្រីម្នាក់ទៀតគឺលោក ផោរ ថងភ័ន់ ជាអ្នកទទួលខុសត្រូវក្នុងការបញ្ជូនសារឆ្លងកាត់ចំការកៅស៊ូនីមួយៗ ដែលបានបាត់ខ្លួនមុនអាយុនៅក្នុងគ្រោះថ្នាក់ចរាចរណ៍កាលពីឆ្នាំ១៩៥២ ។ ព្រះរាជូបត្ថម្ភរបស់ព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ដែលព្រះអង្គទ្រង់យកព្រះទ័យទុកដាក់យ៉ាងខ្លាំងនៅក្នុងផលប្រយោជន៍នៃឧស្សាហកម្មយូរអង្វែង និងជាអ្នកនាំចូលរូបិយប័ណ្ណ នៅតែមិនប្រែប្រួល: ព្រះកិត្តិនាម ដែលមិនអាចប្រកែកបាននៅក្នុងសង្គមជនបទ ដោយសារព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល បានបង្អួលគុណៈងាយស្រួលមួយចំណែកដល់ចំការកៅស៊ូរដ្ឋ និងមួយចំណែកទៀតដល់ចំការកៅស៊ូឯកជនតូចតាចដែលស្ថិតនៅជុំវិញរោងចក្រដែលមានស្រាប់ ។

កិច្ចខិតខំប្រឹងប្រែងនេះ ដែលបានដាក់បញ្ចូលទៅក្នុងគំរោងគោលនយោបាយប្រកបដោយមហិច្ឆតារបស់រដ្ឋាភិបាលកម្ពុជាឱ្យឡើងខ្ពស់បំផុតនៅឆ្នាំ១៩៧០ ត្រូវបានបញ្ឈប់ទៅវិញដោយសារព្រឹត្តិការណ៍សោកនាដកម្ម ដែលបានធ្វើឱ្យប្រទេសជាតិដួលរលំអស់រយៈពេលជិត២០ឆ្នាំ ។

ដោយបានវិលត្រឡប់មកកាន់កម្ពុជាវិញ នាឆ្នាំ១៩៨៩ គឺជាមួយនឹងភាពញញើតញញើមដែលយើងទទួលបាន ភរិយាខ្ញុំ និងរូបខ្ញុំ បានធ្វើទស្សនកិច្ចតាម

រថយន្ត ដោយមានការការពារ នៅចំការកៅស៊ូជុប ដោយឆ្លងកាត់ខេត្តកំពង់ចាម និងឆ្លងកាយសាឡាងទន្លេបិទ ដែលដូចកាលពីមុនដែរ ធ្លាប់បានផ្ទុកផលិតផលនៅតាមដងទន្លេមេគង្គ ។ ដំណើររបស់យើងនៅក្នុងចំការកៅស៊ូជុប បានកាត់បន្ថយឱ្យនៅតិចបំផុតជាមួយនឹងទិដ្ឋភាពឯកោនៃរោងចក្រដែលខ្ទេចខ្ទាំដោយសារការទម្លាក់គ្រាប់បែកអាមេរិកកាលពីឆ្នាំ១៩៧០ ។ មូលហេតុនៃដំណើរប្រញាប់ប្រញាល់នេះបានធ្វើឱ្យយើងដឹងនៅពេលត្រឡប់មកវិញ នោះគឺអ្នកជំនាញការសូវៀតពីររូបបានទទួលរងគ្រោះដោយការឡោមព័ទ្ធកាលពីថ្ងៃម្សិលមិញ ។

ជាមួយនឹងមធ្យោបាយទន់ខ្សោយដែលខ្លួនមាន អាជ្ញាធរជំនាន់នោះបានខិតខំធ្វើអាជីវកម្មដើមកៅស៊ូដែលមានស្រាប់ឡើងវិញ ។ អាជ្ញាធរបានចាប់ផ្តើមរៀបចំកម្មវិធីដាំដុះកៅស៊ូឡើងវិញ ចាប់តាំងពីឆ្នាំ១៩៨៦មក និងបានរៀបចំសាងសង់ភូមិកម្មករឡើងវិញបានខ្លះៗ តាមរយៈជំនួយសហប្រតិបត្តិការរបស់សូវៀត ។

ដូច្នេះ ស្ថិតនៅក្នុងបរិបទដ៏លំបាកលំបិននេះ សាធារណរដ្ឋបារាំងបានសម្រេចផ្តល់នូវជំនួយបច្ចេកទេសដល់ផ្នែកកៅស៊ូចាប់តាំងពីឆ្នាំ១៩៩២មក ដើម្បីជួយកម្ពុជាក្នុងការស្តារចំការកៅស៊ូរបស់ខ្លួនឡើងវិញ ។ វិស្វករក្សេត្រវ័យក្មេងម្នាក់ គឺលោកហ្វីលីពម៉ូណាំង បានបញ្ចេញសកម្មភាពមិនចេះនឿយហត់ដើម្បីបំពេញស្នាដៃនេះ ។ ដោយមានការជួយគាំទ្រដ៏គួរឱ្យកោតសរសើរពីលោកស្រីឡូរ៉ង់ ដែលជាភរិយាដ៏ក្លាហានរបស់គាត់ លោក ម៉ូណាំងមិនខ្លាចរអាចំពោះការលំបាកណាមួយឡើយ ។ គាត់បានប្រឈមនឹងភាពទ័លច្រកផ្នែកគតិយុត្តិដែលលំបាកបំផុត ភាពស្មុគស្មាញផ្នែករដ្ឋបាលដែលមិនបានគ្រោងទុកជាមុន និងការបាក់ទឹកចិត្តរបស់មនុស្សដោយចៀសមិនផុត ដើម្បីប្រែក្លាយសកម្មភាពតាមឆន្ទៈរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ក្នុងការបញ្ចូលដំណាំកៅស៊ូទៅក្នុងវិស័យកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា កាលពីក្នុងទសវត្សឆ្នាំ៦០ ។

នៅក្នុងទសវត្សឆ្នាំ២០០០ ទស្សនកិច្ចប្រកបដោយជោគជ័យចំនួនពីរផងជាប់បន្តបន្ទាប់ ដំបូងបានធ្វើឱ្យយើងយល់ដឹងអំពីការលំបាកពីដំបូងនៃគំរោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ ហើយក្រោយមកចលនាបរាំសរហូតដែលកសិករបានប្រញាប់ប្រញាល់ដើម្បីចក់ឱកាសក្នុងការអភិវឌ្ឍជាឥណទាន ដែលខ្ញុំនឹកឃើញអំពីការលំបាកក្នុងការពន្យល់ដល់ប្រជាពលរដ្ឋដែលរស់នៅដាច់ឆ្ងាយអំពីបរិបថធនាគារ និងយន្តការនៃការគណនាសម្រាប់រយៈពេលវែង ។

នៅទីបំផុត ការវិវត្តន៍នៃស្ថានភាពដាំដុះកៅស៊ូត្រូវបានកែលំអ ចាប់តាំងពីការខិតខំលើកដំបូងនៃកិច្ចសហប្រតិបត្តិការ ។ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង និងអគ្គនាយកដ្ឋានកៅស៊ូ បានខិតខំរួមគ្នានៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ដើម្បីប្រែក្លាយឱ្យទៅជាប្រភពនៃការលូតលាស់ចំការកៅស៊ូគ្រួសារបច្ចុប្បន្ន ។

**អេដែន ហ៊ីស្មេត**

Chevalier de la Légion d'Honneur

Grand Officier de l'Ordre Royal du Cambodge

គោលបំណង គឺធ្វើឱ្យដំណាំកៅស៊ូអាចមានលទ្ធភាពចូលទៅដល់កសិករតូចតាច ដើម្បីផ្តល់នូវប្រាក់ចំណូលបន្ថែមដល់គ្រួសារកសិករនៅកម្ពុជា និងដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គមជនបទផង ។ មិនតែប៉ុណ្ណោះ ដំណាំកៅស៊ូអាចធ្វើជាកាតាលីករនៃការអភិវឌ្ឍជនបទ ដែលបានធ្វើពិពិធកម្ម និងបានផ្សារភ្ជាប់ជាមួយនឹងទីផ្សារ ។ នេះគឺជាគោលដៅរួមនៃគំរោង "ដំណាំកៅស៊ូគ្រួសារ" ដែលអគ្គនាយកដ្ឋានកៅស៊ូបានបង្កើតឡើង ចាប់តាំងពីឆ្នាំ១៩៩៩ ដោយមានការជួយទ្រទ្រង់ពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ។

វិស័យកៅស៊ូបានរីកចម្រើននៅកម្ពុជាអស់រយៈពេលជិត១០០ឆ្នាំមកហើយ នៅលើគំរូតែមួយនៃចំការកៅស៊ូឧស្សាហកម្មធំៗ ដូចនៅបណ្តាប្រទេសភាគច្រើនក្នុងតំបន់ដែរ ។ ទោះបីជាបណ្តាប្រទេសទាំងនោះបានធ្វើការអភិវឌ្ឍនៅក្នុងទសវត្សឆ្នាំ៦០_៧០ ចូលដល់ចំការកៅស៊ូគ្រួសារប្រកបដោយជោគជ័យ ដើម្បីបំពេញបន្ថែម និងពង្រីកផ្ទៃដីដាំដុះក៏ដោយ ក៏ប្រវត្តិសាស្ត្រថ្មីៗនៅកម្ពុជាមិនទាន់មានការវិវត្តន៍របៀបនេះនៅឡើយ ។

គំរោង "ដំណាំកៅស៊ូគ្រួសារ" ដែលបានរៀបចំឡើងកាលពីឆ្នាំ១៩៩៩ ដោយយកចំការកៅស៊ូឧស្សាហកម្មធ្វើជាស្នូល បានដំណើរការនៅក្នុងបរិបទមួយដ៏លំបាក គឺការខ្វះខាតភាពប៉ិនប្រសប់ តម្លៃកៅស៊ូធម្មជាតិមិនសូវមានការទាក់ទាញ ការពិចារណាក្នុងរយៈពេលខ្លីរបស់កសិករកម្ពុជា ។

ការចាំបាច់ ត្រូវមានជំនឿស៊ប់ មានការបញ្ចុះបញ្ចូល និងមានកម្រិតសុទិដ្ឋិនិយមពីអ្នកជំនាញបច្ចេកទេស ដើម្បីឱ្យកសិករមានទំនុកចិត្តក្នុងការលះបង់ដីចំការរបស់ខ្លួនពីមួយទៅពីរ ឬច្រើនហិកតាសម្រាប់ដាំកៅស៊ូ ដែលជារុក្ខជាតិផ្តល់តែទឹកជ័រ និងប្រាក់ចំណូលក្នុងរយៈពេល៥_៦ ឬ ៨ឆ្នាំខាងមុខ ។ នេះគឺជាការសម្រេចចិត្តមួយដោយប្រថុយប្រថាននៅក្នុងការមិនសូវយល់ដឹងពីសំណាក់កសិករភាគច្រើន ។ ក្រុមអនុវត្តគំរោងបានបង្កើតឱ្យមានទំនាក់ទំនងទំនុកចិត្តរវាងកសិករជាមួយក្រុមអ្នកត្រួសត្រាយដាំកៅស៊ូមុនគេមួយ ដែលបានបង្កើតឋាមភាពនេះ និងបានរៀបចំអស់រយៈពេលជាច្រើនឆ្នាំនៅក្នុងខេត្តកំពង់ចាម ដែលជាដើមកំណើតប្រវត្តិសាស្ត្រដ៏យូរលង់នៃដំណាំកៅស៊ូនៅកម្ពុជា ។ ដើម្បីឱ្យការគិតគូរក្លាយទៅជាការជាក់ស្តែង នោះក៏ជាប្រវត្តិសាស្ត្ររបស់មនុស្សផងដែរ ។ មនុស្សដែលបានជួបគ្នា និងដែលបានក្លាយទៅជាអ្នកត្រួសត្រាយរួមគ្នាកាលពីដើមសតវត្សនេះ នៅពេលដែលចំការកៅស៊ូលើកដំបូងត្រូវបានបង្កើតឡើងនៅតំបន់ជុប ។

សៀវភៅ និងរូបថតទាំងនេះ ដែលបានរៀបចំឡើងដោយអ្នកថតរូបវ័យក្មេងកម្ពុជា បានបង្ហាញអំពីប្រវត្តិដំណាំកៅស៊ូ ជាមួយនឹងសកម្មភាពអនុវត្តរបស់គំរោងក្នុងការផ្តល់នូវកូនកៅស៊ូប្រកបដោយគុណភាព ការជួយទ្រទ្រង់បច្ចេកទេសដើម្បីពង្រីកនូវជំនាញថ្មីៗ ការផ្តល់ឥណទានរយៈពេលវែងសម្រាប់កសិករដែលគ្មានមធ្យោបាយដាំដុះ និងការបង្កើតចំការកៅស៊ូគ្រួសារមួយដែលមានគុណភាពលើផ្ទៃដីជិត៤.០០០ហិកតា សម្រាប់ប្រកួតប្រជែងជាមួយចំការកៅស៊ូឧស្សាហកម្ម ។ ប៉ុន្តែ នេះគឺជាប្រវត្តិសាស្ត្ររបស់មនុស្ស និងជាពិសេសប្រវត្តិសាស្ត្ររបស់បុរសនិងស្ត្រីដែលមានជំនឿនៅក្នុងពិពិធកម្មនេះ និងដែលឥឡូវនេះបានចាប់ផ្តើមប្រមូលផលពីចំការរបស់ខ្លួនជាបណ្តើរៗហើយ ។

# កម្ពុជាៈ ទឹកដីនៃដំណាំកៅស៊ូ

ប្រទេសកម្ពុជាបានចាប់ផ្តើមដាំកៅស៊ូនៅឆ្នាំ១៩១០ ។ ជាមួយគំនិតផ្តួចផ្តើមជាលក្ខណៈឯកជន ចំការកៅស៊ូលើកដំបូងត្រូវបានបង្កើតឡើងនៅស្រុកព្រៃនប់ នាតំបន់មាត់សមុទ្រភាគនិរតីជិតកំពង់ផែរាម ។ ប៉ុន្តែដោយសារខ្យល់ និងភ្លៀងច្រើនពេក បណ្តាលឱ្យចំការកៅស៊ូសាកល្បងលើកដំបូងនេះ ទទួលបានទិន្នផលទាប និងបានបោះបង់ចោល ។ ទោះបីជាយ៉ាងណាក៏ដោយ ស្នាកស្នាមនៃចំការកៅស៊ូនេះ បានបន្សល់ទុកនូវអនុស្សាវរីយ៍រហូតមកដល់ទសវត្សឆ្នាំ៩០ ។

នៅឆ្នាំ១៩២០ ជាមួយនឹងការជាប់ពាក់ព័ន្ធរបស់ធនាគារបារាំងធំមួយនៅជំនាន់នោះ ការអភិវឌ្ឍ "ចំការកៅស៊ូឧស្សាហកម្ម"លើកដំបូងត្រូវបានបង្កើតឡើងនៅខេត្តកំពង់ចាមត្រើយខាងជើងនៃទន្លេមេគង្គ ដែលមានផ្ទៃដីមួយផ្នែកធំគ្របដណ្តប់ទៅដោយព្រៃឈើមិនទាន់ធ្វើអាជីវកម្ម និងចំការកប្បាសចាស់ៗ ។ ចំការកៅស៊ូឧស្សាហកម្មលើកដំបូងត្រូវបានបង្កើតឡើងនៅតំបន់ជុប នាឆ្នាំ១៩២២ ដែលមានផ្ទៃដីសម្បទានជិត ១៧.០០០ ហិកតា ។ ក្រុមហ៊ុនកម្ពុជាមួយ [Campagnie du Cambodge] ត្រូវបានបង្កើតឡើងជាផ្លូវការដើម្បីគ្រប់គ្រងចំការកៅស៊ូនេះ ។



ថ្នាលបណ្តុះកូនកៅស៊ូក្នុងថង់នៅចំការកៅស៊ូជួបនាចុងទសវត្សឆ្នាំ៥០ ក្នុងពេលដែលឧស្សាហកម្មកៅស៊ូ ត្រូវបានរស់ឡើងវិញតាមរយៈកិច្ចសហប្រតិបត្តិការជាមួយវៀតណាម



ការប្រមូលទឹកជ័រ ក្រោមម្លប់ដើមកៅស៊ូ



ដំណាំកៅស៊ូ និងដីក្រហម ជាគូនឹងគ្នា

អ្នកដាំកៅស៊ូបានសំដែងឲ្យឃើញអំពីការយល់ដឹងយ៉ាងជាប់ហើសចំពោះគុណភាពដ៏ល្អនៃដីក្រហមបាសាល់សម្រាប់ដំណាំកៅស៊ូ ។ ដោយសារដីពណ៌ក្រហមនេះ កសិករបានប្រែក្លាយអត្ថន័យនៃដីនេះបន្តិចម្តងៗទៅជាមានន័យថា "ជោគជ័យ" ។ ពាក្យ "ដីក្រហម" ដ៏ល្បីល្បាញត្រូវបានគេទទួលស្គាល់យ៉ាងជាប់ហើសនៅក្នុងសង្គមអ្នកដាំកៅស៊ូទូទាំងពិភពលោក ។ នៅក្នុងទសវត្សឆ្នាំ៣០ វិនិយោគិនជាច្រើនបានចូលមកកម្ពុជា ដើម្បីស្វែងរកតំបន់ "ដីក្រហម" នេះ ។ មិនយូរប៉ុន្មាន ចំការកៅស៊ូមេមត់ ចំការកៅស៊ូចំការអណ្តូង ចំការកៅស៊ូព្រែកកក់ បានប្រកួតប្រជែងគ្នាលើផ្នែកបច្ចេកទេស ។ ជាមួយនឹងចំការកៅស៊ូជុប ដែលជារៀមច្បងរបស់ខ្លួន ។ មេមត់បានក្លាយទៅជាចំការកៅស៊ូលើកដំបូងលើពិភពលោក ក្នុងការដាំកូនកៅស៊ូ និងបានផលិតចេញជាជ័រកៅស៊ូ ក្រោមនាមសញ្ញា "Mimotex" ដែលមានន័យថា "គុណភាព ល្អឥតខ្ចោះ" ។ ចំការកៅស៊ូចំការអណ្តូង បានដាំនៅលើតំបន់ដែលមានដីជ្រៅ និងមានជីជាតិ ។ នៅព្រែកកក់ ដើមកៅស៊ូបានដាំជាជួរបន្ទាត់តោងតាមស្ថានភាពនៃតំបន់ភ្នំ ដែលមើលទៅឃើញហាក់ដូចជាផ្សៀងពីលើជ្រលងនិងទន្លេមេគង្គ ។ ចំការកៅស៊ូនេះបានទទួលមោតកសញ្ញាជាជា "ចំការកៅស៊ូដ៏ល្អបំផុតនៅឥណ្ឌូចិន" ។ ក៏ប៉ុន្តែ ចំការកៅស៊ូជុប នៅតែក្សោបផ្ទៃដីធំជាងគេទាំងអស់ ដល់ទៅ១៥.០០០ហិកតា ដោយបានទទួលទិន្នផលខ្ពស់ ជាប់ជាឯកទគ្គកម្មយ៉ាងទៀងទាត់រហូតមកដល់ឆ្នាំ១៩៧៥ ។

ខេត្តកំពង់ចាមទាំងមូល បានទទួលផលប្រយោជន៍ពីចំការកៅស៊ូទាំងនេះ ។ គ្រប់ផ្នែកសេដ្ឋកិច្ចទាំងអស់ត្រូវបានពង្រីកធំឡើង និងធ្វើឲ្យមានសកម្មភាពទីផ្សារ ដែលដឹកនាំដោយបណ្តាសហគ្រាសធំៗ ដោយមានព្រលានយន្តហោះផ្ទាល់ខ្លួន សាលារៀន បណ្តាញផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ។ មន្ទីរពេទ្យនៅចំការកៅស៊ូព្រែកកក់មានកេរ្តិ៍ឈ្មោះល្បី ហើយអ្នកជំងឺជាច្រើនបានចូលមកព្យាបាលនៅក្នុងបន្ទប់វះកាត់ដ៏ទំនើបបំផុត នាសម័យនោះ ។

ការកាន់កាប់របស់ជប៉ុននៅក្នុងសង្គ្រាមលោកលើកទីពីរ បានបង្ខំឲ្យក្រុមហ៊ុនចំការកៅស៊ូធ្វើការវិនិយោគនៅទីកន្លែង ។ កាលនោះ រោងចក្រអគ្គិសនីធំៗបានកើតឡើង ដែលអាចមានសមត្ថភាពផ្គត់ផ្គង់ភ្លើងដល់គ្រប់ភូមិ លំនៅឋាន ការិយាល័យ និងរោងចក្រកែច្នៃជ័រកៅស៊ូ ។ ស្ថានីយ៍បូមទឹកបានបូមទឹកជម្រៅជិត៨០ម៉ែត្រក្រោមដីក្រហមដើម្បីបង្ហូរទឹកទៅគ្រប់តំបន់ដីសម្បទាន ។ បណ្តាញផ្លូវថ្នល់ជិត ៨០០គីឡូម៉ែត្រនៅក្នុងចំការកៅស៊ូជុប ត្រូវបានកសាងឡើងយ៉ាងរឹងមាំ ។



មជ្ឈមណ្ឌលរដ្ឋបាល និងឧស្សាហកម្មនៃចំការកៅស៊ូជុប

ជាមួយនឹងឯករាជ្យភាពនាឆ្នាំ១៩៥៣ ប្រភេទទីពីរនៃចំការកៅស៊ូឧស្សាហកម្មត្រូវបានបង្កើតឡើង នោះគឺចំការកៅស៊ូរដ្ឋ ។ ដំបូង ក្រុមហ៊ុនស្តូលបានធ្វើការដាំដុះកៅស៊ូនៅក្នុងខេត្តក្រចេះ ។ បន្ទាប់មកចំការកៅស៊ូសំបូរគ្រាន់បានបោះទីតាំងនៅលើខ្ពង់រាបនៃដីក្រហមតូចមួយ ស្ថិតនៅភាគខាងលិចខេត្តកំពង់ចាមក្បែរចំការកៅស៊ូចំការអណ្ដូង ។ ចំការកៅស៊ូទាំងនេះដែលគ្រប់គ្រងដោយជនជាតិបារាំង មានការរីកចម្រើនជាលំដាប់ ។ ដើម្បីបំបែកភាពផ្ដាច់មុខចេញពីចំការកៅស៊ូឧស្សាហកម្មធំៗ ចំការកៅស៊ូរដ្ឋទាំងនេះ ក៏បានបើកទស្សនវិស័យធ្វើវិបុលកម្មផ្ទៃដីដាំដុះកៅស៊ូ ។ ប្រភេទចំការកៅស៊ូទីបីបានកកើតឡើងនៅក្នុងទសវត្សឆ្នាំ៦០ ជាមួយនឹងការកើតឡើងនៃអ្នកដាំកៅស៊ូឯកជនកម្ពុជាជាលើកដំបូង ដែលដីចំការទាំងនោះ ត្រូវបានពង្រីកនៅក្បែរដីសម្បទានឧស្សាហកម្មធំៗ និងស្ថិតនៅក្រោមចំណុះចំការកៅស៊ូធំៗ ក្នុងការកែច្នៃជ័រកៅស៊ូរបស់ខ្លួន ។ ប្រជាជនកម្ពុជាបានប្រមូលផ្ដុំគ្នាទៅជាមហាគ្រួសារនៃអ្នកដាំកៅស៊ូ ដែលក្នុងនោះ មួយចំនួនគ្រប់គ្រងចំការកៅស៊ូខ្នាតធំដែលមានផ្ទៃដីលើសពី១.០០០ហិកតា និងមួយចំនួនទៀតគ្រប់គ្រងចំការកៅស៊ូខ្នាតមធ្យម ឬតូច ដែលមានពីក្រោមមួយហិកតាឡើងទៅ ។



សន្តិសុខដែលផ្តល់ដោយចំការកៅស៊ូឧស្សាហកម្មគឺជាប្រភពនៃគ្រួសារកម្មករទៀងដើរ ។
អាពាហ៍ពិពាហ៍រវាងបុគ្គលិកចំការ កៅស៊ូកាន់តែច្រើនឡើង នៅទសវត្សឆ្នាំ៥០





រោគសញ្ញានៃស្លឹកកៅស៊ូជាសញ្ញាដ៏សំខាន់ សម្រាប់សំគាល់អំពីជម្ងឺកៅស៊ូ



វិទ្យាស្ថានស្រាវជ្រាវ និងមន្ទីរពិសោធន៍បានបង្កើតឡើង នៅចំកណ្តាលចំការកៅស៊ូជុប ក្នុងខេត្តកំពង់ចាម



វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលបានកើតឡើងដំណាល គ្មានទីផ្ទាំងកកជ្យ បានឈានមុខនៅក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍ ។ វិទ្យាស្ថានបានបើកការដ្ឋានបង្កើតកូនកៅស៊ូកម្ពុជា និងបានបណ្តុះបណ្តាល អ្នកស្រាវជ្រាវ ។ អ្នកវិទ្យាសាស្ត្រមកពីគ្រប់សញ្ជាតិចំនួនជាង៧៥នាក់បាន ធ្វើការប្រឡងប្រណាំងគ្នា ដើម្បីកែលំអផលិតផល គុណភាព ការការពារ ជម្ងឺ និងល្បឿននៃកំណើនដំណាំកៅស៊ូដ៏មានតម្លៃ ។ វិធីសាស្ត្រទំនើបត្រូវ បានយកមកប្រើប្រាស់ ដូចជាបច្ចេកទេសផ្សាំចំលងទឹកដោះ ជាមួយការបាន ទី១៤ ដើម្បីស្វែងយល់អំពីទឹកជ័រហូរចូលក្នុងកំប៉ុងដោយរបៀបណា ។ វិទ្យាស្ថានបានទទួលផលប្រយោជន៍ពីចំការកៅស៊ូរបស់ខ្លួននៅតាប៉ៅ លើ ខ្ពង់រាបដីក្រហមតូចមួយ ស្ថិតនៅខាងជើងចំការកៅស៊ូជុប ។









ការស្រាវជ្រាវលើសរីរសាស្ត្រកៅស៊ូ ដោយប្រើប្រាស់វិទ្យុសកម្ម radios-isotopes.

នៅពេលនោះផងដែរ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចចិត្តមួយ ដើម្បីពង្រីកជោគជ័យនៃសេដ្ឋកិច្ចជាតិឲ្យដល់បណ្តាខេត្តដែលនៅឆ្ងាយដាច់ស្រយាល ។ ចំការកៅស៊ូរដ្ឋនៅខេត្តរតនគិរីបានចាប់បដិសន្ធិក្រោយគេនៅសម័យនោះ និងដែលបានផ្អាកទៅវិញ ស្របគ្នានឹងការធ្លាក់ចុះនៃសន្តិសុខនៅក្នុងប្រទេស ហើយបន្ទាប់មកសង្គ្រាមបានចូលមកកម្ពុជា ។ នៅឆ្នាំ១៩៧១ ចំការកៅស៊ូទាំងអស់ត្រូវបានបោះបង់ចោល ។ បន្ទាប់មកចំការកៅស៊ូត្រូវបានគ្រប់គ្រងពីភ្នំពេញ និងបានបន្តផលិត ដោយចេញផុតបន្តិចម្តងៗពីការត្រួតពិនិត្យរបស់សមាគមអ្នកដាំកៅស៊ូ ។ ផ្ទៃដីចំនួន៧៥.០០០ហិកតា ដោយរួមទាំងផ្ទៃដីឲ្យផលនិងមិនទាន់ឲ្យផលផង ត្រូវទទួលរងគ្រោះដោយសារការប្រយុទ្ធគ្នា និងការធ្វើអាជីវកម្មតាមបែបអាណាធិបតេយ្យ អស់រយៈពេលជិត២០ឆ្នាំ ។ ចំការកៅស៊ូឯកជនថ្មីៗដែលនៅមិនទាន់ឲ្យផល និងពិបាកការពារ បានទទួលរងគ្រោះដោយសារជម្លោះមុនគេ ។ ចំការកៅស៊ូទាំងនេះត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ។

ជាមួយគ្នានេះ ផលិតផលកៅស៊ូកម្ពុជាបានបាត់មុខពីទីផ្សារអន្តរជាតិក្នុងពេលដែលឧស្សាហកម្មកៅស៊ូកម្ពុជាបានក្លាយជាអ្នកត្រួសត្រាយមុនគេលើការស្រាវជ្រាវ និងលើគុណភាពនៃផលិតផលកៅស៊ូ ។ វាហាក់បីដូចជាប្រទេសនេះបានធ្លាក់ចូលទៅក្នុងសម័យកាលមួយដ៏លំបាក និងច្របូកច្របល់ ។



ពីដើមកៅស៊ូទៅដល់ការប្រមូលផល ។ ធាតុសំខាន់ពីរ ដែលមិនអាចផ្តាច់ចេញពីខ្សាចាននៃដំណាំកៅស៊ូ គឺទឹកជ័រ និងចានត្រងជ័រ ។



កៅស៊ូបង្កក និងកកិតជាបន្ទះ មុននឹងយកទៅសម្ងួត

ទីផ្សារកៅស៊ូកម្ពុជាបានចាប់ផ្ដើមឡើងវិញនៅចុងទសវត្សឆ្នាំ៨០ នៅពេលដែលពាណិជ្ជករសិង្ហបុរីបានប្រើប្រាស់បច្ចេកទេសគួរឱ្យភ្ញាក់ផ្អើលមួយ ដោយបានរៀបចំដាក់លក់កៅស៊ូកម្ពុជា ក្រោមស្លាកសញ្ញា CSK (Caoutchouc Spécifié du Kampuchea) នៅលើទីផ្សារអន្តរជាតិ ។ បរិមាណកៅស៊ូមានតិចតួចណាស់ ។ ការថែទាំលក្ខខណ្ឌពាណិជ្ជកម្មនៅមិនទាន់មាន ហើយផលិតផលកៅស៊ូមិនសូវមានគុណភាពទៀតផង ។ នៅដើមឆ្នាំ១៩៩១ អតីតនាយកក្រុមហ៊ុនចំការកៅស៊ូជុប ចុងក្រោយ ដែលបានភៀសខ្លួនចូលស្ថានទូតបារាំង កាលពីខែមេសា ឆ្នាំ១៩៧៥ បានវិលត្រឡប់មកកន្លែងចាស់របស់គាត់វិញ ។ គាត់មានក្ដីរំភើប ភ្ញាក់ផ្អើល ដោយបានស្គាល់សហការីចាស់ៗដែលបានទៅទទួលគាត់នៅពេលចុះពីយន្តហោះ ។ គាត់បានសង្កេតឃើញដើមកៅស៊ូនៅទីនោះស្ថិតនៅដដែល ។ ជាឡោះរយៈពេល១៥ឆ្នាំកន្លងផុតទៅ មិនបានធ្វើឱ្យមានការផ្លាស់ប្ដូរទម្លាប់ចាស់ឡើយ ដោយអ្នកចៀរជ័រនៅតែចាប់ផ្ដើមធ្វើការតាំងពីម៉ោង៦ព្រឹកដដែល ។ នៅតាមភូមិ គ្មានអគ្គិសនី គ្មានទឹក ។ រោងចក្រមិនដូចកាលពីមុនឡើយ ។ ប៉ុន្តែចំការកៅស៊ូនៅដំណើរការតាមធម្មតា ។ ជាមួយការជួបលើកដំបូង គឺជាការចាប់ផ្ដើមនៃកិច្ចសន្យាមួយដែរ ។ អាជ្ញាធរកម្ពុជាបានជួបជាមួយក្រសួងការបរទេសបារាំង និងបានចាប់ផ្ដើមពិភាក្សាអំពីកិច្ចសហប្រតិបត្តិការនៅអនាគត ។

ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស គំរោងមួយក៏ត្រូវបានចុះហត្ថលេខាដែរ បន្ទាប់ពីក្រុមសិក្សាស្រាវជ្រាវបានបំពេញបេសកកម្មជាច្រើនដងក្នុងរយៈពេលមួយឆ្នាំ ដើម្បីស្វែងយល់ និងសិក្សាអំពីលទ្ធភាពអាចធ្វើបាន ។ នៅខែតុលា ឆ្នាំ១៩៩២ "គំរោងនីតិសម្បទារចនាសម្ព័ន្ធផលិតកម្មកៅស៊ូ" មួយត្រូវបានបង្កើតឡើងនៅអគ្គនាយកដ្ឋានចំការកៅស៊ូ ដែលជាអង្គភាពកណ្ដាលមានតាំងពីមុនមក ។ គោលដៅមានភាពងាយស្រួល តែជំនាញប្រាជ្ញាតឹងឯបញ្ជាក់ និងវាយតម្លៃអំពីស្ថានភាពនៃវិស័យកៅស៊ូ លើកស្ទួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូឡើងវិញ បណ្ដុះបណ្ដាលអនាគតមន្ត្រីនៅតាមចំការកៅស៊ូ កែលំអការដាំដុះ និងបច្ចេកទេសចៀរជ័រឡើងវិញ ។



មធ្យោបាយមានតិចតួច ប៉ុន្តែទឹកជ័រនៅតែហូរជានិច្ច ។ ស្លាបព្រាបង្ហូរទឹកជ័រដែលជាទូទៅធ្វើពីដែក ត្រូវបានជំនួសដោយស្លឹកកៅស៊ូងាប់



ចំការកៅស៊ូនស្សាបាកម្ពុស្វែងរកស្ថិរភាព ក្នុងពេលដែលសន្តិសុខត្រូវបានរៀបចំនៅខាងក្រៅ ក្នុងទសវត្សឆ្នាំ៧០ និង៨០ ។ ការផលិតខាងក្នុងជំរុញធ្វើពីដីផុត នៅចំការកៅស៊ូជុប



មរតកពីអតីតកាល ។ អគារទីចាត់ការចំការកៅស៊ូចុះចានប្រែក្លាយជា អគារបដិសណ្ឋារកិច្ចប្រណីត

ចំការកៅស៊ូទាំងអស់នៅតែស្ថិតនៅក្រោមការគាំទ្ររបស់អគ្គនាយកដ្ឋានចំការកៅស៊ូដដែល ក្រៅពីនោះគ្មានចំការកៅស៊ូឯកជនទេ ។ ផ្ទុយពីបណ្ដាប្រទេសផលិតកៅស៊ូនៅក្នុងតំបន់ វិស័យកៅស៊ូកម្ពុជាត្រូវបានបង្កើតឡើងស្ទើរ១០០%ជាចំការកៅស៊ូឧស្សាហកម្ម ។ ផ្ទៃដីជាង៧៥.០០០ហិកតា ដែលជាតួលេខមុនព្រឹត្តិការណ៍សោកនាដកម្ម នៅសល់ប្រហែលជា ៤៥.០០០ ហិកតាប៉ុណ្ណោះ ។ គ្មានតួលេខណាមួយច្បាស់លាស់ទេ ហើយលទ្ធផលនៃទិន្នផលក៏មិនអាចទុកចិត្តបាន ។ ផលិតផលមានត្រឹមតែពី ៤០.០០០តោន ទៅ ៥០.០០០តោនប៉ុណ្ណោះ ។ ទោះបីជាយ៉ាងនេះក៏ដោយ "ដីក្រហម" ដ៏ល្បីល្បាញបានបញ្ជាក់ច្បាស់អំពីកិត្តិស័ព្ទរបស់ខ្លួន ។ ដើមកៅស៊ូនៅតែល្អ ទោះបីជាមានការបាត់បង់តិចតួច អាស្រ័យដោយសារខ្វះការថែទាំក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកក៏ដោយ ។ គុណភាពនៃក្សេត្រវិទ្យារបស់ដើមកៅស៊ូ រួមផ្សំជាមួយរដូវប្រាំងដ៏វែង បានកាត់បន្ថយយ៉ាងច្រើននូវការយាយីពីជម្ងឺនៅលើដើមកៅស៊ូ ។ ស្ថានភាពដ៏ល្អនៃដើមកៅស៊ូទាំងនេះហាក់ដូចជាបានលុបបំបាត់ស្លាកស្នាមនៃប្រវត្តិសាស្ត្ររបស់ប្រទេសនេះ ។ ឡូត៍កៅស៊ូដាំនៅឆ្នាំ ១៩២៤, ១៩២៥, ១៩២៦, ១៩២៧ សល់តែ២០០ដើមប៉ុណ្ណោះក្នុងមួយហិកតា ។ ឡូត៍ទាំងនេះបានទៀត និងបានផលិតជាប់ជានិច្ច ។ ដើមកៅស៊ូមួយចំនួនមានទំហំធំៗ និងមានមុខទៀបវាស់ទៅជាង១.៨០ម៉ែត្រ ដែលតាមទម្លាប់នៅក្នុងចំការកៅស៊ូឧស្សាហកម្មធម្មតាមួយ ប្រវែងមុខទៀរមានតែ៧០សង់ទីម៉ែត្រប៉ុណ្ណោះ ។

ទោះបីជាយ៉ាងណាក៏ដោយ ការធ្វើឲ្យមានសំទុះឡើងវិញ មានការលំបាកដោយសារចំណេះដឹងថ្មីៗ ដែលអ្នកជំនាញក្នុងក្រុមទ័ណ្ឌកិច្ចសហប្រតិបត្តិការនាំមក បានប្រឈមទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលដ៏តឹងរ៉ឹង និងមិនមានបំណងផ្លាស់ប្ដូរទម្លាប់ចាស់ឡើយ ។ ការមិនមានបំណងផ្លាស់ប្ដូរទម្លាប់ចាស់ បានធ្វើឲ្យការអនុវត្តន៍ជាក់ស្ដែងមិនមានតម្លាភាព និងមិនឆ្លើយតបទៅនឹងទីផ្សារអន្តរជាតិ ។ ការអភិវឌ្ឍជំណាំកៅស៊ូ ស្ថិតនៅឆ្ងាយពីសក្ដានុពលពិតប្រាកដរបស់ខ្លួន ។ ការនាំចេញបានកម្រិតចំពោះផលិតផលពាក់កណ្ដាលសម្រេច ដូចជា"ជ័រកក" ដែលជាជ័របានបង្កកទុក ប៉ុន្តែមិនបានហាល ។ ស្ថានភាពមិនល្អនៃរោងចក្រ និងការចាត់តាំងមិនច្បាស់លាស់ បានបញ្ជាក់អំពីការកត់សំគាល់ខាងលើនេះ ។ ដូច្នេះតម្លៃបន្ថែមដែលបានមកពីការកែច្នៃជ័រកកទៅជាកៅស៊ូដុំ បានធ្លាក់ទៅក្នុងដៃអ្នកនាំចូលនៅប្រទេសជិតខាង ។



ឧប្បត្តិហេតុដែលមានជាញឹកញាប់ក្នុងរោងចក្រមានកំហុសខ្លាំង ។ ទឹកជ័រកកក្នុងស៊ីឡែន ។ ត្រូវតែយកចេញ



ទឹកជ័រការ ។ ការលាងទឹកជ័រមួយកំប៉ុងដើម្បីវាយតម្លៃធាតុកៅស៊ូ និងចាត់ស្មានបរិមាណអាស៊ីតចាំបាច់ សំរាប់ធ្វើការបង្កក



កៅស៊ូត្រូវបានវេចខ្ចប់ ត្រៀមសំរាប់ធ្វើការនាំចេញ



ភាពស្ងប់ស្ងាត់នាពេលរសៀល នៅក្នុងចំការកៅស៊ូ

នៅក្នុងស្ថានភាពដ៏លំបាក គំរោងសហប្រតិបត្តិការបានទទួលជោគជ័យក្នុងការរៀបចំការនាំចេញកៅស៊ូតាមគុណតំរូវលើកដំបូងតាមបទដ្ឋានអន្តរជាតិ ។ ចាប់ផ្តើមពីខែសីហា ឆ្នាំ១៩៩៣ កៅស៊ូកម្ពុជាត្រូវបានកែច្នៃជាផលិតផលសម្រេច ដែលសំណាកជាច្រើនត្រូវបានដាក់តាំងនៅមជ្ឈមណ្ឌលវប្បធម៌បារាំងនាដើមឆ្នាំ១៩៩៤ ។ ភស្តុតាងបានបង្ហាញថាវិស័យកៅស៊ូបានស្ថិតនៅលើមាគ៌ានៃការកសាងឡើងវិញ ។

ក្នុងបរិបទនេះ លទ្ធផលដំបូងជាវិជ្ជមាន និងប្រកបដោយអត្ថន័យនៃកិច្ចសហប្រតិបត្តិការ បានស្តែងឲ្យឃើញនូវតួលេខនៃលំហូរវត្ថុធាតុដើមមិនបានកែច្នៃ ។ ប៉ុន្តែលទ្ធផលនេះ បង្កឲ្យមានការប្តឹងតវ៉ា និងមានប្រតិកម្មតបមកវិញ ។ នៅដើមឆ្នាំ១៩៩៤ តួលេខលំហូរវត្ថុធាតុដើមមិនបានកែច្នៃបានឈានដល់អត្រាដ៏ខ្ពស់ ។ វិធានការមួយត្រូវបានអនុវត្តឡើងភ្លាមនៅចុងឆ្នាំ១៩៩៤ ដោយអនុញ្ញាតឲ្យនាំចេញតែជ័រកៅស៊ូស្ងួតប៉ុណ្ណោះ ចំណែកឯជ័រកកត្រូវតែធ្វើការកែច្នៃនៅតាមបណ្តារោងចក្រកម្ពុជា ។



បន្ទាប់ពីទឹកជ័រ ឈើកៅស៊ូ គឺជាគោលទ្រព្យទីពីរ ដែលអាចប្រើប្រាស់ធ្វើជាអុស ឬជាគ្រឿងសង្ហារឹម ។

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាបានទទួលផលប្រយោជន៍ពីជំនួយរបស់មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្ម និងអភិវឌ្ឍន៍អន្តរជាតិបារាំង (CIRAD: Centre de Recherche Agricole et de Développement) ។ ក្រុមក្សេត្រវិទូ និងវិស្វករនៅតាមចំការកៅស៊ូ បានទទួលការបណ្តុះបណ្តាលពីអ្នកជំនាញជាច្រើនដែលធ្វើការនៅក្នុងតំបន់នេះ ដើម្បីជាមាគ៌ាស្តារឡើងលើកម្រិតដើមឡើងវិញ ។ ផែនការដាំដុះជាថ្មីឡើងវិញត្រូវបានកែសម្រួល ។ ការវិនិច្ឆ័យគឺមានភាពច្បាស់លាស់ៈ គេត្រូវការរយៈពេល ១០ឆ្នាំក្នុងការកាប់ ការដាំឡើងវិញ ការលុបចោលនូវស្នាកស្នាមសង្គ្រាម និងការទិតទំស្វែងរកកេរ្តិ៍ឈ្មោះដ៏រុងរឿងពីអតីតកាលឡើងវិញ ។

ចាប់ពីចុងទសវត្សឆ្នាំ៩០ ទិដ្ឋភាពដែលកើតមាននោះ គឺការកាប់ដើមកៅស៊ូចាស់ៗ ។ គ្មានអ្វីមកបញ្ឈប់ការរីកចម្រើនបានឡើយ ។ ដើមកៅស៊ូចាស់ៗដែលបានដាំកាលពីឆ្នាំ១៩២៤ចំនួន១៤.៩៥ហិកតាត្រូវបានរក្សាទុក ដោយកំណត់នាមជា "សារមន្ទីរ" ។ ដើមកៅស៊ូចាស់ៗទាំងនេះ គឺជាទីកន្លែងទស្សនកិច្ចមួយ ដែលមិនអាចបំភ្លេចបានសម្រាប់ភ្ញៀវទាំងឡាយដែលបានមកទស្សនាដើម្បីឱ្យស្គាល់ចំការកៅស៊ូជុប ។




សក្ខីកម្មមួយ ។ ក្នុងចំណោមដើមកៅស៊ូខ្សែក្រហមធំៗចំណាស់ជាងគេ ចំនួន១៤,៩៥ហិកតា គឺកៅស៊ូដាំដោយគ្រាប់ ក្នុងឆ្នាំ១៩២៤ ត្រូវបានរក្សាទុកដោយក្រុមប្រឹក្សាភិបាលក្នុងចំការកៅស៊ូជុប ។ ដើមកៅស៊ូ ទាំងនេះរស់នៅបានរហូតដល់វ័យចំណាស់គួរឱ្យកោតសរសើរ និងត្រូវបានរៀបរក្សាទុកតាំងពីឆ្នាំ១៩៩៨

ផ្ទុយទៅវិញ ការដាំដុះកៅស៊ូឡើងវិញបានជួបការលំបាកយ៉ាងខ្លាំង ។ ព្រោះពេលវេលានៃដើមកៅស៊ូមិនទាន់ឲ្យផលមានការទាក់ទងនឹងផលវិនិយោគធ្ងន់ធ្ងរ ដែលមានវិសមិតភាពជាមួយពេលវេលាដែលកំពុងត្រូវការយ៉ាងច្រើននៅក្នុងសេដ្ឋកិច្ចកំពុងស្តារឡើងវិញ ។ ផៃដីចៀរជ័របានកាត់បន្ថយពីមួយឆ្នាំទៅមួយឆ្នាំ ។

តម្លៃកៅស៊ូបានឡើងខ្ពស់ ចាប់ពីឆ្នាំ១៩៩៤បានធ្វើឲ្យអ្នកដាំកៅស៊ូតូចតាច និងឯកជនចាប់ផ្តើមដាំដុះជាថ្មី ។ ផៃដីថ្មីនេះបានជំនួសមួយផ្នែករបស់ផ្នែកឧស្សាហកម្មរដ្ឋដែលបានថយចុះ ។ ការកែលំអនេះ មានរយៈពេលខ្លី ហើយនៅឆ្នាំ១៩៩៧ ទីផ្សារកៅស៊ូបានធ្លាក់ចុះ សកម្មភាពនៃធនធានរបស់វិនិយោគិនគ្រប់ផ្នែកមិនបានសម្រេចឡើយ ។

ស្ថិតក្នុងរយៈពេលដ៏លំបាកនេះ អាជ្ញាធរជាន់ខ្ពស់បានសម្រេចស្នើសុំឲ្យទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ផ្លាស់ប្តូរទិសដៅគំរោង និងសុំឲ្យជួយគិតគូរជួយដល់គ្រួសារកសិករស្ម័គ្រចិត្ត ដើម្បីឲ្យចូលរួមដាំកៅស៊ូ ។ រដ្ឋាភិបាលបារាំងក៏បានឯកភាពលើគំនិតនេះ ។ ដូច្នេះ គំរោងបានចាប់ផ្តើមដំណើរការ ។



អគារដែលបាក់បង់នៅ ។ ស្លាកស្នាមនៃជម្លោះនៅតែជាក់ស្តែង ។ ស្លាកស្នាមទាំងនេះបានបាត់បង់ទៅជាមួយនឹងការដាំដុះកៅស៊ូឡើងវិញ នាដើមឆ្នាំ ២០០០



មុខកាប់ដែលនៅសល់ ។ ការរៀបចំការងារ ។ កម្មករចៀរជ័រម្នាក់ៗមានលេខសំគាល់មួយ និងសញ្ញាសម្រាប់ចៀរ



ការបំប៉នកូនកៅស៊ូនៅក្នុងថ្នាល គឺជាសកម្មភាពគន្លឹះមួយនៃការផលិតកូនកៅស៊ូ។

ទោះបីជាមានផលប៉ះពាល់ផ្នែកបច្ចេកទេស និងនយោបាយយ៉ាងណាក៏ដោយ គំរោងអភិវឌ្ឍន៍ចំណាំកៅស៊ូគ្រួសារបានចាប់ផ្តើមនៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៩៩ បន្ទាប់ពីការទៅមកបារីស-ភ្នំពេញអស់រយៈពេលជាង ១៨ខែ ។ គោលដៅសាមញ្ញ នោះគឺការរៀបចំយុទ្ធនាការដាំដុះកៅស៊ូចំនួន ៣ឆ្នាំលើផ្ទៃដី ១៤០០ហិកតា តាមរយៈការផ្តល់ឥណទានដែលធានាដោយការដាក់បញ្ចាំប័ណ្ណដី ។

ឧបសគ្គធំៗពីរបានកើតឡើងនៅក្នុងសប្តាហ៍ដំបូង ។ ទីមួយគឺឧបសគ្គសង្គម ។ ប្រជាកសិករបានទទួលរងការធ្វើជាតូបនីយកម្មដីធ្លីលើកដំបូងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានបន្តមកដល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សេចក្តីសង្ស័យលើនេះរបស់រដ្ឋក្នុងការអនុញ្ញាតឲ្យដាំកៅស៊ូជាលក្ខណៈឯកជនមិនបានស្តារឡើងវិញឡើយ ។ ទីពីរគឺឧបសគ្គផ្នែករដ្ឋបាល ។ ការបែងចែកដីកសិកម្មជាផ្លូវការមិនអាចពឹងផ្អែកទៅលើការបោះបង្គោលព្រំដីដែលមិនទាន់មាននៅឡើយ ។ គឺមានតែបង្កាន់ដៃកាន់កាប់មួយប៉ុណ្ណោះ ដែលអាចប្រើប្រាស់បាន ។ ប៉ុន្តែមិនអាចយកមកប្រើជាផ្លូវការបានឡើយ ហើយគ្មានកសិករណាម្នាក់ធ្វើជាម្ចាស់កម្មសិទ្ធិលើដីដែលខ្លួនកំពុងកាន់កាប់ជាផ្លូវការដែរ ។ ការធានាដែលជាលក្ខខណ្ឌរបស់ធនាគារអភិវឌ្ឍន៍ជនបទក្នុងការបើកឥណទានគឺមិនមានឡើយ ។

ផលវិបាកនៃដំណើរការអនុវត្តកម្មវិធីមានការលំបាក ។ ផ្ទៃដីចំនួន ២២ហិកតាត្រូវបានអនុវត្តនៅក្នុងយុទ្ធនាការទីមួយ លើផែនការគ្រោងទុក ២០០ហិកតា ។ ចំពោះការរៀបចំយុទ្ធនាការឆ្នាំ២០០០ ភ្នាក់ងារគំរោងបានប្រែក្លាយទៅជាក្រុមបេសកជនដើម្បីចុះផ្សព្វផ្សាយដល់មូលដ្ឋាន ។ ក្បួនគ្រូសាស្ត្រ និងបច្ចេកទេសចំណាំកៅស៊ូបានស្ថិតនៅឆ្ងាយពីបន្ទុករបស់អ្នកជំនួយការបច្ចេកទេស ។ យុទ្ធនាការនេះបានដំណើរការ តែមិនទាន់គ្រប់គ្រាន់នៅឡើយ ។ មានផ្ទៃដីចំនួនតែ៧១ហិកតាប៉ុណ្ណោះ ដែលបានធ្វើការដាំដុះរួចលើផែនការ៤០០ហិកតា ។

នៅក្នុងយុទ្ធនាការទាំងពីរលើកនេះ ប័ណ្ណដីធ្លីក៏នៅមិនទាន់បានផ្តល់ឲ្យនៅឡើយ ទោះបីជាចំណាំកៅស៊ូបានដុះលូតលាស់រួចហើយក៏ដោយ ។ ភាពប៉ិនប្រសប់ ការនិយមចូលចិត្ត និងសុទិដ្ឋិនិយមយ៉ាងធំ ជាតម្រូវការចាំបាច់របស់មនុស្ស ប៉ុន្តែលើសពីនេះទៅទៀត ឆន្ទៈគ្មានទីបញ្ចប់របស់ពួកគេ គឺចង់បានការបើកឥណទានមួយដោយគ្មានការធានា ។ នៅក្នុងសភាពជាក់ស្តែង ការបែងចែកប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធទៅឲ្យកសិករបានកើតឡើងជាលើកដំបូងនៅក្នុងកំណែទម្រង់ដីកសិកម្ម ប៉ុន្តែអាជ្ញាធរនៅមូលដ្ឋានមិនទាន់បានត្រៀមខ្លួនទទួលខុសត្រូវលើការងារនេះនៅឡើយ ។ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំងបានលើកឡើងនូវលក្ខខណ្ឌមួយគឺ ផ្ទៃដីជាង៣០០ហិកតាត្រូវតែដាំឲ្យបាននៅក្នុងយុទ្ធនាការឆ្នាំ២០០១ បើមិនដូច្នោះទេគំរោងត្រូវចាត់ទុកជាបរាជ័យ និងត្រូវបញ្ឈប់ជាបន្ទាន់ ។



ចំការកៅស៊ូមានការរៀបចំខ្សែករបស់វា ដូចខ្សែកងការទេសភាពស្អាត ។ ដោយពឹងផ្អែកលើកសិកម្ម ជាមួយដើមកៅស៊ូ និងលើឧស្សាហកម្ម ជាមួយចំការកៅស៊ូ ចំការកៅស៊ូបានបង្ហាញផ្លូវជីវិតលក្ខណៈអភិវឌ្ឍន៍ចំនួនផ្ទៃដីប្រហែល១១លានហិកតា គឺស្មើនឹង ៤.៤០០លានដើម នៅក្នុងពិភពលោក

បន្ទាប់ពីលើកពាក់កណ្តាលនៃទសវត្សរ៍ អ្នកបច្ចេកទេសនៃគំរោងបានចាប់ផ្តើមផ្លាស់ប្តូរយ៉ាងជាប់លាប់ក្នុងទម្លាប់នៃវិស័យកៅស៊ូ ដូចជាការផលិតកូនកៅស៊ូបំប៉ៅដោយគ្មានការទាក់ទងជាមួយចំការកៅស៊ូឧស្សាហកម្ម ។ ជំនួសវិញនេះ អ្នកធ្វើថ្នាលបណ្តុះកូនកៅស៊ូត្រូវបានធ្វើការបណ្តុះបណ្តាល ដែលក្រោយមកពួកគេបានផលិតកូនកៅស៊ូសម្រាប់កសិករដាំកៅស៊ូតូចតាច ។ ប៉ុន្តែឧបសគ្គធំមួយបានកើតឡើងយ៉ាងឆាប់ ដោយសារតែមានតម្រូវការកាន់តែច្រើនឡើងនៃមែកបំប៉ៅ ដែលមានប្រភពច្បាស់លាស់ពីច្បារពូជរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូ ។ ករណីនេះបានធ្វើឲ្យគំរោងជួបប្រទះនូវហានិភ័យ ដោយសារមិនអាចធានាបាននូវគុណភាពកូនកៅស៊ូដែលគំរោងបានផ្តល់ដល់កសិករ ។ ការសម្រេចចិត្តមួយមិនអាចជៀសបាន ។ បន្ទាប់ពីបានបណ្តុះបណ្តាលអ្នកធ្វើថ្នាលបណ្តុះកូនរួចមក អ្នកទទួលខុសត្រូវគំរោងបានចាប់ផ្តើមធ្វើការបណ្តុះបណ្តាលអ្នកធ្វើច្បារពូជ និងបានរៀបចំបង្កើតច្បារពូជជាលក្ខណៈឯកជនឡើង ។ ជោគជ័យគឺបានកើតឡើងយ៉ាងច្បាស់ ដោយហេតុថាក្នុងយុទ្ធនាការដាំដុះទាំងបីនេះ "អ្នកដាំកៅស៊ូតូចតាច" បានទទួលនូវឯករាជ្យរបស់ខ្លួនពីចំការកៅស៊ូឧស្សាហកម្ម ក្នុងការផ្គត់ផ្គង់កូនកៅស៊ូ ។

ជាមួយគ្នានេះដែរ ដោយមានទំនាក់ទំនងនៅគ្រប់តំបន់នៃគំរោង កសិករបានធ្វើលិខិតជូនដល់តំណាងជាប់ឆ្នោតរបស់ខ្លួន និងដោយមានការធ្វើអន្តរាគមន៍ផ្សេងៗពីថ្នាក់ដឹកនាំនៃគំរោងគ្រប់ថ្នាក់ នៅទីបំផុតកសិករបានទទួលផលរបស់ខ្លួន ។ នៅខែសីហា ឆ្នាំ២០០០ ប្រមុខរដ្ឋាភិបាលបានតម្រង់ទិសឲ្យមានការអភិវឌ្ឍន៍ចំការកៅស៊ូគ្រួសារឡើងវិញ ។ ប័ណ្ណដីធ្លីបានចាប់ដំណើរការឡើងវិញ កសិករមានទំនុកចិត្តលើគំរោងដែលបានបើកទីស្នាក់ការនៅក្នុងខេត្តកំពង់ចាម ។ យុទ្ធនាការដាំដុះឆ្នាំ២០០១ បានទទួលជោគជ័យ ។ ផ្ទៃដីកៅស៊ូចំនួន៣៥០ហិកតាត្រូវបានដាំរួចរាល់ ។ ចំពោះមុខការចាប់ផ្តើមថ្មីនេះ និងដោយមានតម្រូវការដាំដុះកាន់តែច្រើន រដ្ឋាភិបាលទាំងពីរគឺកម្ពុជា និងបារាំងក៏មានការពេញចិត្តពេញទៅវិញទៅមក ហើយបានសម្រេចចិត្តប្រកបដោយសុទិដ្ឋិនិយមនិងបន្តគំរោងនេះតទៅទៀត ។



ដើមកៅស៊ូមួយដើម ដែលបើកមុខចៀរដំបូងបានបញ្ជាក់អំពីការបញ្ចប់រយៈពេលមិនទាន់ឱ្យផល ។ ការចៀរពីរពន្លាកដំបូង គ្មានឱ្យអ្វីទេ ។ ត្រូវរង់ចាំបន្ទាប់ពីបីឆ្នាំ ទើបទទួលទឹកជ័រ បន្ទាប់ពីការរង់ចាំរយៈពេល៥ឆ្នាំ ឬ៦ឆ្នាំ

នៅឆ្នាំ២០០២ រោងចក្រកែច្នៃកៅស៊ូឯកជនលើកដំបូងបានកើតឡើង ។ រោងចក្រទាំងនេះបានបើកទីផ្សារសម្រាប់អ្នកដាំកៅស៊ូឯកជន រហូតដល់ធ្វើឱ្យរោងចក្ររបស់រដ្ឋស្ថិតនៅឯកោ ដែលជាញឹកញាប់ រោងចក្រឯកជននេះបានអនុវត្តតម្លៃទិញជ័រខ្ពស់គួរឱ្យភ្ញាក់ផ្អើល ហើយប្រៀបធៀបទៅនឹងតម្លៃលក់នៅផ្សារអន្តរជាតិ ។ ឆ្លើយតប ទីផ្សារអន្តរជាតិ ដែលបានខិតខំប្រឹងប្រែងផ្ដោតលើឯកទេសកម្ម ក៏បានកើនឡើង ។ ទីបំផុត ការតាលីករគ្រប់គ្រាអនុគ្រោះទាំងនេះបានលេចឡើង នោះគឺ៖ នៅឆ្នាំ១៩៩៩ អ្នកដាំកៅស៊ូលើកដំបូងរបស់តំរោងចំនួន១៩នាក់ ដែលបានដាំដុះលើចំនួន២២ហិកតា បានចាប់ផ្តើមបើកមុខចៀរកៅស៊ូតាំងពីខែធ្នូ ឆ្នាំ២០០៤ បន្ទាប់ពីរយៈពេលមិនទាន់ឱ្យផលចំនួន៥ឆ្នាំកន្លះ ។ រហូតដល់ពេលនេះ អ្នកដែលមានសុទិដ្ឋិនិយមភាគច្រើនបានយករយៈពេលមិនទាន់ឱ្យផលជាមធ្យមចំនួន៧ឆ្នាំ ទោះបីជាដើមកៅស៊ូទាំងនោះជាទម្លាប់ត្រូវបានចៀរក្រោយការដាំដុះរយៈពេល៨ឆ្នាំក៏ដោយ ។ ទិន្នផលជ័រកៅស៊ូដំបូងមានចំនួន៨០០គីឡូក្រាមក្នុងមួយហិកតា ដែលមិននឹកស្មានដល់ ។ អ្នកដាំកៅស៊ូមួយចំនួនបានចាប់ផ្តើមសងប្រាក់កម្ចីនៅពេលបានទទួលផលលើកដំបូងរបស់ខ្លួន ដោយមិនព្រមទទួលយករយៈពេលអនុគ្រោះ៨ឆ្នាំ ដែលធនាគារបានផ្តល់ឱ្យក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងជាមួយទីភ្នាក់ងារអភិវឌ្ឍន៍បារាំងឡើយ ។ នៅក្នុងស្ថានភាពពិសេសនៃផលិតផលនេះ ប្រាក់ចំណូលបានកើនលើសពី១០០០ដុល្លារក្នុងមួយហិកតា សម្រាប់ការងារ១០០ថ្ងៃក្នុងមួយឆ្នាំ ។ ប្រជាកសិករបានទទួលជោគជ័យនិងកាន់តែមានជំនឿចិត្ត ។

យុទ្ធនាការក្រោយៗបានបន្តព្រមៗគ្នាដោយគ្មានបសក្តិ ក្នុងការដាំដុះកៅស៊ូដោយទៀងទាត់ចំនួន៥០០ហិកតាក្នុងមួយឆ្នាំ នៅឆ្នាំ២០០៤ ២០០៥ និង២០០៦ ។ ចំនួនកសិករស្ម័គ្រចិត្តចេះតែកើនឡើង ដែលចាំបាច់ត្រូវតែពិនិត្យឡើងវិញនូវលក្ខណសម្បត្តិនៃការជ្រើសរើសកសិករ ដែលបញ្ហានេះបានបង្កឱ្យមានការតវ៉ាពីសំណាក់កសិករខ្លះដែលសុំមកចុះឈ្មោះ ។ ជោគជ័យលាន់ពេញនៃគំរោងបានខ្ទរផុតពីព្រំដែននៃខេត្តកំពង់ចាមហើយ ។ បណ្ដាខេត្តដែលស្ថិតនៅជុំវិញបានរកឃើញតំបន់ដាំដុះកៅស៊ូ ទោះបីជាដីក្រហម ឬមិនមែនក៏ដោយ ។ គំរោងមិនអាចឆ្លើយតបគ្រប់សំណើសុំដាំដុះបានឡើយ ។ ប៉ុន្តែ ដោយហេតុថាគំរោងធ្លាប់បានអនុវត្តនៅក្នុងតំបន់អាស៊ី ដូច្នេះត្រូវបានគេយកមកផលិតចម្លងតាម និងបង្កើនបន្ថែមទៀត ។ ផ្អែកតាមគំរូរបស់គំរោង ថ្នាលបណ្ដុះកូនកៅស៊ូបានកើតឡើងស្ទើរគ្រប់ទីកន្លែង ច្បារកូនកៅស៊ូក៏បានកើនឡើងយ៉ាងខ្លាំង ។ ចាប់ពីទំហំ៥០ហិកតានៃចំការកៅស៊ូដាំដោយឯកជននៅឆ្នាំ២០០៤ កសិករដែលមិនបានទទួលប្រាក់កម្ចី ឬជំនួយបច្ចេកទេសពីគំរោង បានដាំដុះកៅស៊ូរហូតដល់ជាង ១៥.០០០ហិកតា នៅឆ្នាំ២០០៧ ។ ដូច្នេះ ហាមភាពឯកជនក្នុងស្រុកបានសម្រាលគុណវិបត្តិរបស់ស្ថាប័ន ។

ទន្ទឹមនឹងជោគជ័យផ្នែកបច្ចេកទេស គំរោងបានដឹកនាំ រៀបចំ និងគាំទ្រឱ្យមានការបង្កើតសមាគមវិជ្ជាជីវៈនៃអ្នកដាំកៅស៊ូឯកជនចំនួនបួន ។ សមាគមទាំងនេះជាតំណាងនិងការពារនៃផ្នែកឯកជន ។ ប្រធានសមាគមត្រូវបានបោះឆ្នោតដោយសមាជិកអ្នកដាំកៅស៊ូនៅក្នុងគំរោង ។ នៅពេលខាងមុខសមាគមទាំងនេះនឹងចាប់ផ្ដើមបំពេញការងាររបស់ខ្លួន រួមមាន ការរៀបចំបើកសាលាបង្រៀនចៀរជ័រ និងការបែងចែកជី ដែលជាផ្នែកមួយយ៉ាងសំខាន់នៃប្រាក់កម្ចី ។ ដូច្នេះ ស្ទើរតែទាំងអស់នៃកសិករជាង១០០០គ្រួសារដែលបានយល់ព្រមតាមគោលការណ៍ និងការទាមទាររបស់គំរោង បានបង្កើតទៅជាក្រុមតូចមួយជំពូកនៃរចនាសម្ព័ន្ធវិជ្ជាជីវៈនេះ ។ កសិករទាំងនេះបានយល់ដឹងពីអត្ថប្រយោជន៍ក្នុងការចុះឈ្មោះនៅក្នុងសមាគមវិជ្ជាជីវៈដែលអាចធ្វើជាតំណាងនិងលក់ផលគេប្រកបដោយប្រសិទ្ធភាពនៅពេលផ្ដល់ផលនៃដើមកៅស៊ូបានចូលមកដល់ ។



ថ្នាលបណ្ដុះកូនកៅស៊ូដែលធ្លាប់ជាកម្មសិទ្ធិផ្តាច់មុខរបស់ចំការកៅស៊ូរដ្ឋពីមុនមក ។ ក្នុងរវាងឆ្នាំ២០០០ នេះភាពភាគច្រើនបានទៅដោយថ្នាលបណ្ដុះកូនកៅស៊ូឯកជន

ហាមភាពនៃយុទ្ធនាការមានភាពគួរឱ្យចាប់អារម្មណ៍ ។ ហាមភាពនេះបានទាក់ទាញអ្នករស់នៅទីក្រុងផងដែរ ដោយបានឃើញនៅក្នុងវិរយោគមួយនេះថា ជាការត្រាស់ត្រូវដ៏ធំមួយសម្រាប់ចលនានៃអចលនទ្រព្យរបស់ខ្លួន ។ ស្ថិតនៅក្នុងភូមិកន្លែងនេះ គំរោងបានខិតខំប្រឹងប្រែងមិនត្រឹមតែការធានាគុណភាពសម្រាប់កសិករតូចតាចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្សព្វផ្សាយច្បារកូនដើម្បីធ្វើឱ្យដីទាំងនេះគ្របទៅដោយដំណាំកៅស៊ូដែលមានគុណភាពទៀតផង ។ ច្បារកូនទាំងនេះដែលបានបង្កើតឡើងដើម្បីបង្កើនកូនកៅស៊ូ បានក្លាយទៅជាចំណុចកណ្ដាលនៃភូមិកន្លែងមុនគេ ។ គំរោងបានចាប់ផ្ដើមធ្វើការសន្ទនាលើកដំបូងលើការងារដែលបានអនុវត្តហើយ ។ ក្រុមកសិករបានបង្កើនប្រាក់ចំណូលរបស់ខ្លួនយ៉ាងឆាប់រហ័ស និងបានប្រមូលផ្ដុំគ្នានៅក្នុងសមាគមដែលពួកគេបានដឹកនាំ ។ ឥឡូវនេះ ការយល់ដឹងពីសញ្ញាណកូនកៅស៊ូបានចូលរួមយ៉ាងពេញលេញជាមួយនិងជោគជ័យនៃការដាំដុះផងដែរ ។ ការបង្កើនចំនួនថ្នាលបណ្ដុះកូនត្រូវធ្វើឡើងដោយម្ចាស់ការ ។ ប៉ុន្តែ មូលដ្ឋាននៃផ្នែកសិក្សាប្រកបដោយគុណភាពនេះត្រូវបានបោះបង់ចោល ។ ដូច្នេះ គេត្រូវតែរៀបចំកម្មវិធីថ្នាក់ជាតិមួយដែលនឹងផ្ដល់ផលប្រយោជន៍ហាមភាពជាឧទាហរណ៍នេះដល់បណ្ដាខេត្តដទៃទៀត ។

ជាការគួរឱ្យសោកស្ដាយ តម្រូវការបណ្ដុះដីសម្រាប់ផានាតណាទាំ បានស្ថិតនៅឆ្ងាយពីរដ្ឋបាលស្រុកយោធីដែលអាចផ្ដល់ឱ្យបាន ។ គំរោងដែលស្ថិតក្នុងចន្លោះចង្អៀតនៅខេត្តកំពង់ចាម មិនមានឱកាសនឹងពង្រីកកាលជាលើគ្រប់ទីកន្លែងបានឡើយ ។ គំរោងបានដើរហួសដល់ខេត្តក្រចេះ ដែលមានអតីតចំការកៅស៊ូរដ្ឋមួយកន្លែងនៅស្រុកស្នួល លើទ្ធនិកបត្តមួយ ប៉ុន្តែមិនអាចទៅឆ្ងាយទៀតបានឡើយ ។ ការខិតខំរបស់គាត់ទាំងពីរដើម្បីពង្រីកកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យកៅស៊ូនៅតែឥតបានការ ។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ គំរោងដែលធ្លាប់មានកិត្យានុភាពអំពីជោគជ័យត្រូវបានបញ្ចប់ ។

គំរោងគំរូកៅស៊ូគ្រួសារបានទទួលជោគជ័យ ក្នុងការបង្កើតច្បារកូនឯកជន ។
ចាប់ពីពេលនោះតទៅ កូនកៅស៊ូទាំងនេះអាចចូលទៅដល់គ្រប់គ្នា ។ អ្នកបច្ចេកទេស
នៃអគ្គនាយកដ្ឋានចំការកៅស៊ូបានបំពេញតួនាទីរបស់ខ្លួនយ៉ាងត្រឹមត្រូវ

ក៏ប៉ុន្តែ មាគ៌ារបស់គាត់កាន់តែបើកចំហឡើង ។ ការជំរុញទ្រទ្រង់ចុងក្រោយរបស់គាត់ដល់សមាគមវិជ្ជាជីវៈមិនអាចនៅតែបន្តទៅទៀតបាន ។ នៅឆ្នាំ២០០៥ សមាគមទាំងមូលបានចាប់ផ្តើមធ្វើការងារតាមបែបស្វយ័ត ។ សមាគមមានទំនួលខុសត្រូវធំៗ មានបញ្ហាប្រឈមតិច ប៉ុន្តែវិស័យកៅស៊ូកំពុងតែរីកដុះដាល និងមានការប្រែប្រួលយ៉ាងខ្លាំង ។ នៅក្នុងឆ្នាំ២០០៨ ជាលើកទីមួយហើយ ដែលតួលេខនៃផ្ទៃដីដាំដុះកៅស៊ូទូទាំងប្រទេស បានកើនដល់ជាង១០០.០០០ហិកតា ។ នេះគឺជាលើកទីមួយដែរ ដែលផ្ទៃដីកៅស៊ូឯកជនបានកើនលើសផ្ទៃដីឧស្សាហកម្ម ។ ជាពិសេស ការងារឯកជនភាវូបនីយកម្មក៏បានប្រព្រឹត្តទៅ ។ អ្នកដេញថ្លៃជាក្រុមហ៊ុនឯកជន ឬជាវិនិយោគិន ដែលមានទ្រព្យសម្បត្តិច្រើនបានទទួលបន្តសកម្មភាពបន្ទាប់ពីចន្លោះពេលជិត៣៥ឆ្នាំដែលរដ្ឋបានដឹកនាំ ។ នៅក្នុងរយៈពេលជិតគំរប់ខួប១០០ឆ្នាំនៃដំណាំកៅស៊ូនៅកម្ពុជានៅឆ្នាំ២០១០ វិស័យនេះបានផ្លាស់ប្តូរទិដ្ឋភាពជាថ្មី ។ ឋានភាពរបស់អ្នកដាំកៅស៊ូឯកជន ទាំងតូច ទាំងធំ និងក្លាយជាអ្នកផ្លុំពន្លត់ទៀន១០០ដើម លើនំខួបកំណើត១០០ឆ្នាំ នៃកៅស៊ូកម្ពុជា ។

ឋានភាពនៃប្រជាកសិករ បានប្រែក្លាយពេញលេញនៅពេលនៃ
ការចាប់ផ្តើមគំរោងនិរន្តរភាពក្នុងការដាំដុះថ្មី



**ឆ្នាំ១៨៧៦**
ការនាំចូលដំណាំកៅស៊ូ ពីប្រទេសប្រេស៊ីល មកកាន់តំបន់អាស៊ី ភាគអាគ្នេយ៍

**១៨៨៩**
ការប្រមូលផលជ័រកៅស៊ូ លើកដំបូងនៅតំបន់អាស៊ី

**ឆ្នាំ១៨៩០**
ការនាំចូលដំណាំ កៅស៊ូទៅតំបន់ អាហ្វ្រិក

**ឆ្នាំ១៨៩៧**
ការនាំចូលដំណាំ កៅស៊ូមកប្រទេស វៀតណាម

**១៨៧៦ > ១៩៥០ : ជំហានដំបូងនៃដំណាំកៅស៊ូ**

១៨៧៦ | ១៨៨៩ | ១៨៩០ | ១៨៩៧

# កាលបរិច្ឆេទសំខាន់ៗនៃដំណាំកៅស៊ូ

**ឆ្នាំ១៩១០**

កៅស៊ូកសិលើកដំបូង ត្រូវបានគេដាំនៅស្រុកស៊ីប

**១៩១៦**

ផលិតផលកៅស៊ូកសិ លើសពីផលិតផលកៅស៊ូ នៃប្រទេសប្រេស៊ីល

**១៩១៨**

ចំការកៅស៊ូលើកដំបូងនិងធំជាងគេ បានសម្រេចសម្រាំង និងបំពេញ ការនៅប្រទេសឥណ្ឌូណេស៊ី

**១៩៣០**

ហេតុផលប៉ះពាល់ដល់សេដ្ឋកិច្ចឆ្នាំ៣០: ចំការកៅស៊ូតូចតាច ឬ ចំការកៅស៊ូគ្រួសារបាន កាន់កាប់ ផ្ទៃដីជាស្ទួតពីចំការកៅស៊ូ ឧស្សាហកម្ម ជិត២.០០០.០០០ ហិកតា លើផ្ទៃដីសរុបប្រមាណជា ៣.៥០០.០០០ហិកតា

**ឆ្នាំ១៩៤៥**

ជាឆ្នាំផុតសង្គ្រាមនៅតំបន់អាស៊ី ។ ផ្ទៃដីចំការកៅស៊ូជាប្រចាំមានចំនួន ៤៦៦.០០០ហិកតា លើផ្ទៃដីកៅស៊ូ សរុប៣.៦៦៥.០០០ហិកតា

| | | | |
|---|---|---|---|
| ១៩១០ | ១៩១៦ | ១៩១៨ | ១៩៣០ |

ក្នុងទសវត្សឆ្នាំ៥០

ការចាប់ផ្តើមបង្កើតចំការកៅស៊ូ
កម្មនៅប្រទេស កូតឌីវ័រ (Côte d'Ivoire)

ឆ្នាំ១៩៦០

ផលិតផលកៅស៊ូសំយោគ ដែលទាញ
យកពីប្រេងនៅមានបរិមាណប្រហាក់ប្រហែល
គ្នានឹងផលិតផលកៅស៊ូធម្មជាតិ

ក្នុងទសវត្សឆ្នាំ៦០

កៅស៊ូកម្ពុជាបាន ទទួលកិត្តិស័ព្ទ
លើគុណភាពដ៏ល្អប្រសើរ ។
បរិមាណជ័រកៅស៊ូ ស្ទើរតែទាំងអស់ត្រូវ
បាននាំចេញទៅអឺរ៉ុប ។

ទសវត្សឆ្នាំ៨០

ផលិតផលកៅស៊ូកម្ពុជាត្រូវបាន
ផ្លាស់ប្តូរជាមួយទំនិញដែលចាំបាច់
យកពីសហភាពសូវៀត និងបណ្តា
ប្រទេសសង្គមនិយម ។

ខែវិច្ឆិកា ឆ្នាំ១៩៩២

ប្រទេសកម្ពុជាត្រូវបានអញ្ជើញឱ្យចូលរួម
ក្នុងសន្និសីទរបស់ក្រុមសិក្សាកៅស៊ូ
អន្តរជាតិ នៅប្រទេសសិង្ហបុរី ។
នេះគឺជាវត្តមានលើកដំបូង ដែលបណ្តា
តំណាងនិងសហគមន៍កៅស៊ូធម្មជាតិបាន
ចូលរួមក្នុងសន្និសីទអន្តរជាតិ ចាប់តាំងពី
ទីក្រុងភ្នំពេញត្រូវបានរំដោះរួចមក ។

ពីចំការកៅស៊ូឧស្សាហកម្ម ទៅចំការកៅស៊ូគ្រួសារ

១៩៥០ ១៩៦០ ១៩៨៨

ឆ្នាំ១៩៧៥

បន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញ
ប្រទេសកម្ពុជាផលិតកៅស៊ូបានចំនួន
៥០.០០០តោនក្នុងមួយឆ្នាំ គឺមានជាង១%
នៃផលិតផលកៅស៊ូពិភពលោក ។

ឆ្នាំ១៩៩០

គ្រប់ក្រុមហ៊ុនចំការកៅស៊ូរដ្ឋបាន
ផលិតកៅស៊ូចំនួន២៥.០០០តោន ។
ការនាំចេញទៅបណ្តាប្រទេស
ជិតខាងនៅមានកំណត់ ។

១៩២០ | ១៩៨០ | ១៩៩២ | ១៩៩៣ | ១៩៩៤ | ១៩៩៥ | ២០០០ | ២០០៥ | ២០០៧ | ២០០៨

### ខែសីហា ឆ្នាំ១៩៩៣

គុណភាពនៃកៅស៊ូកម្ពុជាមានលក្ខណៈសមស្រប តាមបទដ្ឋានបច្ចេកទេសអន្តរជាតិ ត្រូវបាន ដាក់តាំងលក់ជាលើកដំបូងនៅតំបន់ផែក្រុង ព្រះសីហនុ ឆ្ពោះទៅកាន់ទីផ្សារអឺរ៉ុប ។ ប្រទេសកម្ពុជាបានសាកល្បងឈានជើង ចូលក្នុងទីផ្សារកៅស៊ូពិភពលោក ។

### ឆ្នាំ១៩៩៥

ចំការកៅស៊ូនិងសហគ្រាសកម្ពុជាត្រូវបាន ប្រគល់សិទ្ធិឱ្យធ្វើការនាំចេញផលិតផល របស់ខ្លួនដោយស្វ័យភាព ។

### ខែមិថុនា ឆ្នាំ១៩៩៥

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុញ្ញាតឱ្យចំការកៅស៊ូរដ្ឋ កាប់ ដើមកៅស៊ូចាស់ៗក្នុងផែនការ១០ឆ្នាំ និងធ្វើ ការដាំដុះឡើងវិញជាបន្តបន្ទាប់ ។

### ឆ្នាំ២០០០

រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យ កសិករធ្វើការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារ

### ទសវត្សឆ្នាំ២០០០

កៅស៊ូកម្ពុជាភាគច្រើនត្រូវបាននាំចេញទៅ ប្រទេសចិន ។ ការនាំចេញទៅទីផ្សារ អឺរ៉ុប ជប៉ុន ឬសហរដ្ឋអាមេរិកនៅមាន កម្រិតតិចតួចនៅឡើយ ។

### ឆ្នាំ២០០៥

ផ្ទៃដីដាំដុះកៅស៊ូនៅកម្ពុជាមានជាង ១០០.០០០ហិកតា ដែលក្នុងនោះផ្ទៃដី ជាងពាក់កណ្តាលគឺជាចំការកៅស៊ូគ្រួសារ តូចតាច និងឯកជន ។ ផលិតផលកៅស៊ូ កម្ពុជាឡើងដល់៦០.០០០តោន ដែល បរិមាណនេះជិតស្មើនឹង០.៦ភាគរយនៃ ផលិតផលកៅស៊ូពិភពលោក ។

### ខែមិថុនា ឆ្នាំ២០០៧

សន្និសីទកៅស៊ូអាស៊ានលើកទី៣ បានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ៖ កៅស៊ូកម្ពុជាត្រូវបានទទួលការគាំទ្រ នៅលើទីផ្សារអន្តរជាតិ ។ ឆ្នាំ២០០៧ បរិមាណផលិតផលកៅស៊ូធម្មជាតិ ក្នុងពិភពលោក បានកើនឡើងដល់ ៩,៧៣លាន តោន ដែលក្នុងនោះ ប្រទេសថៃ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី មានចំនួន៧២% ។ ចំណែកឯកៅស៊ូសំយោគ មានបរិមាណចំនួន១៣,៥លានតោន ។

### ខែមករា ឆ្នាំ២០០៨

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាត្រូវបាន ទទួលស្គាល់ដោយសមាគមកៅស៊ូ អន្តរជាតិ ( IRA: International Rubber Association) ។ ប្រទេសកម្ពុជាត្រូវបាន ធ្វើសមាហរណកម្មជាផ្លូវការឡើងវិញទៅ ក្នុងបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ដែលមានវិញ្ញាបនកម្មលើគុណភាព ។ បន្ទាប់មក កម្ពុជាបានត្រៀមទទួលនូវការ ដាក់ឱ្យយកទីផ្សារសំខាន់ៗថ្មីទៀត ដែលតម្រូវឱ្យផលិតផលមានគុណភាព ។

### រហូតមកដល់បច្ចុប្បន្ន

សមាមាត្រចំនួន៨៥%នៃកៅស៊ូធម្មជាតិ នៅក្នុងពិភពលោក គឺចេញមកពី ចំការកៅស៊ូគ្រួសារតូចតាច ។

# ដើមកៅស៊ូ ជ័រ និងផលិតផលកៅស៊ូ

កៅស៊ូ ដែលបានប្រើប្រាស់ដោយអារ្យធម៌នៃសង្គមបុរេកូឡុំប៊ី បានទទួលស្គាល់នៅទ្វីបអឺរ៉ុបនៅក្រោមសតវត្សទី១៥ប៉ុណ្ណោះ ។ កម្មសិទ្ធិរូបវ័ន្ត និងគីមីរបស់កៅស៊ូបានផ្តល់យ៉ាងជាប់រហ័សនូវតួនាទីមួយផ្នែកនៅក្នុងបដិវត្តន៍ឧស្សាហកម្ម ។ ដូចគ្នានឹងដែក ធ្យូង និងប្រេងដែរ កៅស៊ូបានក្លាយទៅជា វត្ថុធាតុដើមជាយុទ្ធសាស្ត្រមួយ ។ ប្រសិនជាគ្មានកៅស៊ូទេ សង្គមឧស្សាហកម្ម ទាំងមូលនឹងជួបការលំបាកនៅក្នុងដំណើរការណាស់ ។

ជ័រកៅស៊ូហូរចេញពីសំបកដើមកៅស៊ូ បន្ទាប់ពីបានចៀរតាមរបៀបវង្វង់ស្លឹករ៉ាល់ដោយទៀងទាត់ ។

នៅពេលឱ្យផល រវាងពី៥ និង៧ឆ្នាំ ដើមកៅស៊ូត្រូវបានបែងចែកជាពីរផ្ទាំងមុខចៀរស្មើគ្នា ដែលបានគូសដោយគំនូសបញ្ឈរ ហៅថាគំនូសចែកផ្ទាំងមុខចៀរ ។ នៅចន្លោះគំនូសចែកផ្ទាំងមុខចៀរទាំងពីរ មានគំនូសក្រិតបីទៀតជារបៀបវង្វង់ស្លឹករ៉ាល់ដែលកំណត់ និងកម្រិតអំពីតំបន់ត្រូវចៀរសម្រាប់រយៈពេលពីរឆមាស ។ នៅខាងក្រោមវង្វង់ស្លឹករ៉ាល់ គំនូសចែកផ្ទាំងមុខចៀរត្រូវឆូតជាចង្អូរ និងពង្រីកឱ្យចំចុះមកក្រោមឱ្យដល់ស្លាបព្រា ដើម្បីឱ្យទឹកជ័រហូរចេញពីវង្វង់ស្លឹករ៉ាល់មកដល់ស្លាបព្រា ហើយហូរចូលក្នុងចាន ដែលទ្រដោយលួសទ្រ និងចងភ្ជាប់ដោយខ្សែលួសជាមួយដើមកៅស៊ូ ។ នេះគឺជាសម្ភារៈសម្រាប់ដើមកៅស៊ូ ។ ដូច្នេះ ដើម "បើកមុខចៀរ" ត្រូវបានចៀរលើកដំបូងនៅលើសំបកកំណើតដំបូង ។

ប្រព័ន្ធចៀរជ័រជាច្រើន ត្រូវបានអនុវត្តព្រមៗគ្នាទៅតាមការធ្វើអាជីវកម្មដែលបានជ្រើសរើស ។ ប្រព័ន្ធចៀរជ័រមានការប្រែប្រួលអាស្រ័យដោយសារកត្តាសំខាន់ពីរគឺ ចង្វាក់ចៀរ និងប្រវែងមុខចៀរ ។ ដើមកៅស៊ូអាចចៀរបានក្នុងចន្លោះ២ថ្ងៃម្តង ៣ថ្ងៃម្តង ៤ថ្ងៃម្តង ឬអាចលើសពីនេះ ។ ការបាត់បង់ផលិតផលដែលបណ្តាលមកពីការកាត់បន្ថយចង្វាក់ចៀរជ័រត្រូវបានជំនួសមកវិញ ដោយការប្រើថ្នាំអេទីឡែនលើមុខចៀរ ។ ការចៀរជ័រអាចធ្វើបានតាមរបៀប ចៀរមួយជុំដើម(វង្វង់ស្លឹករ៉ាល់) ពាក់កណ្តាលដើម (១/២ស្លឹករ៉ាល់) ឬមួយភាគបួននៃដើម(១/៤វង្វង់ស្លឹករ៉ាល់) ។ វង្វង់ស្លឹករ៉ាល់អាចចៀរពីសំបកផ្នែកខាងលើចុះមកផ្នែកខាងក្រោម ឬពីសំបកផ្នែកខាងក្រោមឡើងទៅលើវិញ ។

ចំការកៅស៊ូមួយអាចជ្រើសយកប្រព័ន្ធអាជីវកម្ម ដោយគិតគូរជាពិសេសដល់បរិយាកាសសង្គម (ចង្វាក់ចៀរជ័រកាន់តែច្រើន ចំនួនអ្នកចៀរក៏កាន់តែច្រើនដែរ) និងដល់ក្លូនកៅស៊ូដែលត្រូវជ្រើសរើស (ក្លូនអាចទទួលយកចង្វាក់ចៀរជ័រ និងការរំញោចបានតិច ឬច្រើន ) ។

ការជ្រើសរើសប្រព័ន្ធចៀរមានឥទ្ធិពលដោយផ្ទាល់លើការប្រើប្រាស់សំបក និងលើអាយុរបស់ដើមកៅស៊ូ ។ ផ្ទាំងមុខចៀរត្រូវបានអនុវត្តដោយឆ្លាស់គ្នា (ដោយផ្លាស់ប្តូរពីផ្ទាំងមុខចៀរមួយ ទៅផ្ទាំងមុខចៀរមួយទៀតរៀងរាល់មួយឆ្នាំម្តង) ឬពីផ្ទាំងមុខចៀរមួយ បន្ទាប់មកទៅផ្ទាំងមុខចៀរមួយទៀត (បន្ទាប់ពីបានចៀរចប់ផ្ទាំងមុខចៀរទីមួយ ទើបចាប់ផ្តើមបើកផ្ទាំងមុខចៀរទីពីរទៀត) ។

# គំរោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ

## នីតិវិធីនៃការអនុវត្តន៍

កាលពីខែមីនា ឆ្នាំ១៩៩៩ ក្រុមបច្ចេកទេសមួយត្រូវបានបង្កើតឡើង ក្នុងគោលបំណងបង្កើតនូវប្រព័ន្ធការងារស្នូលមួយសំរាប់ចំការកៅស៊ូគ្រួសារ នៅក្នុងខេត្តកំពង់ចាម ។ ក្របខ័ណ្ឌការងារ ដែលបានរៀបចំឡើងតាមរយៈ ការសិក្សាអំពីលទ្ធភាពអាចធ្វើបាន និងលទ្ធផលនៃការវាយតម្លៃរួមដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង បានបង្ហាញនូវទិសដៅបួន ដែលត្រូវអនុវត្តបន្តគឺ:

១. ការរៀបចំប្រព័ន្ធឥណទានរយៈពេលវែងមួយ ដោយផ្តល់នូវធនធានហិរញ្ញវត្ថុដល់គ្រួសារកសិករដែលបានចូលរួមដាំកៅស៊ូ
២. ការបង្កើតប័ណ្ណដីធ្លីដោយស្របច្បាប់ នៅលើដីចំការសម្រាប់ដាំកៅស៊ូ
៣ ការបញ្ចូលវិធីសាស្ត្រដាំដុះថ្មីៗ និងការចែកពិសោធន៍ដើម្បីជួយបង្កើនសេដ្ឋកិច្ចគ្រួសារ
៤. ការជម្រុញ និងការរៀបចំបង្កើតសមាគមវិជ្ជាជីវៈកៅស៊ូដោយឯករាជ្យ

ដំណើរការនេះមានភាពសមស្របណាស់ ។ កសិករទាំងអស់បានទទួលនូវអត្ថប្រយោជន៍ពីឥណទាន (១) ដែលធានាតាមរយៈការដាក់បញ្ចាំប័ណ្ណដីធ្លី (២)និងការសងប្រាក់កម្ចីវិញ នៅពេលដើមកៅស៊ូចាប់ផ្តើមឲ្យផល (៣) ដែលផលិតផលត្រូវបានផ្តល់តម្លៃដោយចូលកាត់តាមសកម្មភាពរបស់សមាគមវិជ្ជាជីវៈ (៤) ដែលពួកគាត់បានចូលរួម ។

នៅតាមបណ្តាមូលដ្ឋាន ក្រុមអនុវត្តគំរោងបានរៀបចំសកម្មភាពយ៉ាងឆាប់រហ័ស ដោយមានគោលដៅពីរយ៉ាងសំខាន់គឺ: កសិករបានប្រកាសនៅចំពោះមុខតំណាងក្រុមអនុវត្តគំរោងដែលបានបង្កើតឡើង (នៅក្នុងមណ្ឌលចំនួន៦នៅក្នុងខេត្តកំពង់ចាម) និងការចុះពិនិត្យស្ថានភាពដីចំការដែលអាចសមស្របនឹងដំណាំកៅស៊ូឬទេ ។ ឯកសារត្រូវបានបញ្ជូនទៅសុរិយោដីដើម្បីពិនិត្យលើមូលភាព(ភាពសមហេតុសមផល) ក្នុងការស្នើសុំប័ណ្ណកាន់កាប់ដីចំការ ។ ធនាគារអភិវឌ្ឍន៍ជនបទធ្វើការវាយតម្លៃអំពីសមត្ថភាពហិរញ្ញវត្ថុរបស់កសិករ ។ ក្នុងករណីដែលលទ្ធផលទទួលបានជាវិជ្ជមាន ផ្នែកសុរិយោដីបានចាត់នីតិវិធីគ្រប់បែបបទ រហូតដល់ការផ្តល់ប័ណ្ណកាន់កាប់ដីចំការនោះ ។ ដូច្នេះ កសិករត្រូវចុះហត្ថលេខាលើកិច្ចសន្យា ជាមួយធនាគារអភិវឌ្ឍន៍ជនបទ និងធានានីតិវិធីក្នុងការដាក់បញ្ចាំ ។ ក្រុមអនុវត្តគំរោងអាចចាប់ផ្តើមដំណើរការដាំដុះកៅស៊ូ ។

# សេចក្តីថ្លែងអំណរគុណ

គំរោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារបានទទួលជោគជ័យដោយសារការចូលរួមរបស់ដៃគូជាច្រើនរួមមាន ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាល បុគ្គល ដែលបានគាំទ្រទាំងជំនួយការងារ បច្ចេកទេស និងថវិកាពេលវេលាចំពោះសកម្មភាពជាច្រើន ដែលបានដំណើរការអស់រយៈពេល១០ឆ្នាំនៅក្នុងការដាំដុះកៅស៊ូ ។ អ្នកជំនួយការបច្ចេកទេសនៃគំរោងដែលមិនអាចរៀបរាប់ឈ្មោះអស់ បានជ្រើសរើសអ្នកដែលមានវត្តមាន និងដែលបានខិតខំបញ្ចេញស្នាដៃដោយផ្ទាល់រហូតដល់គំរោងបានទទួលជោគជ័យ ។

## ស្ថាប័ន

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះឯ.ឧ. ការ់ សេងហុរ ទេសរដ្ឋមន្ត្រី ឯ.ឧ. ឈា សុង អតីតរដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានទទួលមរណភាពឲ្យរំលឹកលោកស្ពាយ ឯ.ឧ.បណ្ឌិត ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ឯ.ឧ. សុខ ឥន្ទ្រ ប្រធានអគ្គនាយក នៃធនាគារអភិវឌ្ឍន៍ជនបទ ឯ.ឧ. កេង ឡៅ រដ្ឋលេខាធិការ ក្រសួងកសិកម្ម និងជាប្រធានគណៈកម្មាធិការប្រតិបត្តិគំរោង ឯ.ឧ. ឡោ រស្មី អគ្គលេខាធិការ ក្រសួងកសិកម្ម និងជាលេខាធិការអចិន្ត្រៃយ៍ នៃគណៈកម្មាធិការប្រតិបត្តិគំរោង លោក បើ វុធី ទទួលបន្ទុកបេសកកម្មនៃធនាគារអភិវឌ្ឍន៍ជនបទ ឯ.ឧ. ម៉ក់ គឹមហុង ប្រធានអគ្គនាយកដ្ឋានកៅស៊ូ និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិគំរោង លោកបណ្ឌិត ម៉ឹក សុង នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិគំរោង លោក ជា សៀវម៉េង ទទួលបន្ទុកបេសកកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិគំរោង ។

## ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង

នាយកទីភ្នាក់ងារទាំងអស់ដែលគ្រប់គ្រងជាបន្តបន្ទាប់ ចាប់តាំងពីការចាប់ផ្ដើមដំណើរការនៃគំរោង ដែលបានគាំទ្រការងារ គំរោងនេះចំពោះមុខឧបសគ្គទាំងឡាយ រួមមាន Madame Geneviève Javaloyès, Madame Marie-Pierre Nicollet, Monsieur Giovalucchi, Monsieur Yves Terracol, Monsieur Eric Beugnot . អ្នកទទួលបន្ទុកបេសកកម្មរបស់ទីភ្នាក់ងារនៅភ្នំពេញដែលមានវត្តមាននៅក្នុងការស្វែងរកដំណោះស្រាយត្រឹមត្រូវ រួមមាន Monsieur Philippe Dierickx, Monsieur Julien Calas, Monsieur Hervé Conan ដែលបានបញ្ចូលគំនិតនៅក្នុងសៀវភៅនេះ និងសម្រាប់ការគាំទ្រជាប្រចាំនៅក្នុងទស្សនវិស័យរបស់អស់លោក ។ ចុងក្រោយ លោក Georges d'Andlau និងលោក Yevan Grouitch អ្នកផ្ដួចផ្ដើមគំរោងលើកដំបូងនៅទីស្នាក់ការកណ្ដាលនៃទីភ្នាក់ងារអភិវឌ្ឍន៍បារាំងនៅប៉ារីស ដោយគ្មានករណីណាមួយមានលទ្ធភាពធ្វើបាន ។

## GRET-CEDAC

ប្រធានគំរោងទាំងអស់ និងអ្នកទទួលបន្ទុកបេសកកម្មដែលបានយកចិត្តទុកដាក់ដោយមានគតិវិជ្ជមាន និងការបំពេញបន្ថែម ព្រមទាំងស្ម័គ្រចិត្តនៅក្នុងការគ្រប់គ្រងឥណទានសម្រាប់អ្នកដាំកៅស៊ូ ការបង្កើត និងការរៀបចំសមាគមវិជ្ជាជីវៈ រួមមាន Monsieur Olivier Huchet, Christophe Le Picard, Frédéric Chastenet, Jean-Marie Brun, Olivier Renard, Sandra Barlet, Brigitte Laedeker, Yann Masurel លោក ហ៊ី ធី លោក អ៊ុំ កាន់ លោក ហឹម សុផាណា ។

## មន្ត្រីសហការគំរោងដំណាំកៅស៊ូគ្រួសារ

លោកជំទាវ ពាន់ ធានី អគ្គប្រឹក្សាពិសេស ដែលភាពម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងបានធ្វើឱ្យកើតមានមូលដ្ឋាននៃដំណើរការប្រចាំថ្ងៃនៃបេសកកម្ម ។ លោក សុក សារ៉ុ ទទួលបន្ទុកបច្ចេកទេសកសិកម្ម អាស្រ័យដោយសារភាពសកម្ម បានធ្វើឱ្យមានផ្ទាំងមូលដ្ឋានផ្ដល់ជូនវិធីសាស្ត្រការបណ្ដុះកូនកៅស៊ូ ។ លោក ហុង វុទ្ធី អ្នកប្រឹក្សាពិសេសការងាររៀបចំ និងដាំដុះដែលចំណេះដឹងផ្នែកដំណាំកៅស៊ូនៅមូលដ្ឋាន និងជីវភាពនៅជនបទកម្ពុជា បានផ្ដល់ជូនវិធីសាស្ត្រសំខាន់ៗដល់សមិទ្ធិកម្មថ្នាលកូន ថ្នាលពន្លកកូនកៅស៊ូ និងការដាំដុះ កៅស៊ូដ៏ប្រសើរ ។ លោក អៀម សារិទ្ធ លោកស្រី យោគ សាម៉ុល និងលោកស្រី សុខ បុប្ផា ទទួលបន្ទុកការងារគណនេយ្យ ដែលការយកចិត្តទុកដាក់ និងភាពរហ័សរហួន បានគាំទ្រការប្រឹក្សាពិគ្រោះនៃចំណាយសម្រាប់ដំណើរការ និងការដាំដុះកៅស៊ូ ។ លោក អ៊ាក ណាងចាន់ ទទួលខុសត្រូវផ្នែកបុគ្គលិក អន្តរាគមន៍ និងវគ្គបណ្ដុះបណ្ដាល ដែលតែងតែស្វែងរកដំណោះស្រាយដ៏ល្អប្រសើរ ចំពោះបញ្ហាលំបាកផ្នែកវគ្គបណ្ដុះបណ្ដាល និងភស្តុភារ ។ លោក ឆេង វណ្ណា ទទួលបន្ទុកផ្នែករបាយការណ៍ប្រចាំខែ និងការសម្រេចសម្រួលគ្រប់គ្រង ។ គ្រប់ប្រធានតំបន់ លោកចាន់ រ៉ាន់ធឿង លោកអ៊ិន អៀង លោកទីវ ណាយហួត លោក ញ៉ូង ហ៊ីម លោក កាន់សំអូន ដែលមិនដែលរារាំងនៅក្នុងមុខតំណែងដ៏លំបាកក្នុងការធ្វើការចេញទៅកាន់គំរោង និងការស្វិតស្វាញរបស់កសិករដាំកៅស៊ូ ។ សម្រាប់បណ្ដាញផ្លូវជាង១៨០គីឡូម៉ែត្រនៅក្នុងខេត្តកំពង់ចាម អ្នកបើកបរទាំងអស់រួមមានលោក វ័ក្ក សារុន លោក គីម ហ្រឹក លោក យស់ កុល លោក កៅ ប៊ុន លោក ហឹម ម៉ៅ លោក ណាង សម្បត្តិ ។ អ្នកបង្ហាត់បង្រៀនផ្នែកកសិកម្ម ដែលបានធានាដល់ប្រសិទ្ធភាពនៃការផ្ទេរបច្ចេកទេសកសិកម្មរវាងអ្នកជំនួយការបច្ចេកទេស និងអ្នកដាំកៅស៊ូគ្រួសារ ។ ចុងក្រោយបំផុត លោក កើត សុវណ្ណរង្សី លេខាធិការ-អ្នកទំនាក់ទំនងផ្លូវរាប់រយគីឡូម៉ែត្រទៅទីក្រុងភ្នំពេញ ។ លោកស្រី នុក សុខុម អ្នកធ្វើអនាម័យ និងរៀបចំកៀវ លោកគង់ ប្រុស អ្នកយាម និងការធានាសន្តិសុខនៅក្នុងទីស្នាក់ការគំរោងអស់រយៈពេល ជាងដប់ឆ្នាំកន្លងមកនេះ ។

សូមថ្លែងអំណរគុណចំពោះកិច្ចសហការរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដោយក្ដីគោរពពី ឯកឧត្តម លី ផល្លា និងលោក ហ្វីលីព ម៉ូណាំង

អ្នកនិពន្ធ: ឯកឧត្តម លើ ផល្លា និងលោក Philippe Monain

នាយកគំរោង: Herve Conan

បណ្ណាធិការ និងរូបភាព: Agence Melon Rouge

អ្នកសម្របសម្រួលបោះពុម្ពផ្សាយ: Alexandre Burgeat

រចនារូបភាព: Béatrice Legrand

កែសម្រួលរូបភាព: Thierry Merré

© Printed on September 2008
JSRC Printing House
Inside the Ground of Boeng Trabek, Monivong Blvd. Phnom Penh Cambodia

បន្ទាប់មកទៀត ចំការកៅស៊ូកម្ពុជាដែលធ្លាប់មានកេរ្តិ៍ឈ្មោះល្បីល្បាញ ពេលបច្ចុប្បន្នជាក់ស្តែង បានទទួលរងការបំផ្លិចបំផ្លាញនៃសង្គ្រាមស៊ីវិលអស់រយៈពេល៣០ឆ្នាំ និងបានបាត់បង់ទីផ្សារពាណិជ្ជកម្មអន្តរជាតិ ។ វិស័យនេះបានចាប់ផ្តើមងើបរស់ឡើងវិញនៅក្នុងទសវត្សរ៍ឆ្នាំ៩០ តាមរយៈការទាក់ទាញឡើងវិញជាមួយស្ថាប័នពហុជាតិ និងដៃគូរបស់ខ្លួន ។

ក៏ប៉ុន្តែ នៅពេលឈានចូលមកដល់ទសវត្សរ៍ថ្មី ចំការកៅស៊ូគ្រួសារ ដែលបានចាប់ផ្តើមរីកដុះដាលឡើងវិញ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ និងដែលបានជំរុញឱ្យមានការផ្លាស់ប្តូរជីវភាពរបស់កសិករ បានធ្វើឱ្យសង្គមកម្ពុជាយើងនេះ ផ្គត់ផ្គង់ទៅលើបណ្តាប្រទេសជិតខាងនៅក្នុងតំបន់ ដែលជាដើមកំណើតដំបូងនៃចំការកៅស៊ូគ្រួសារ ។

ដោយការយកចិត្តទុកដាក់ក្នុងការយកព័ត៌មាន រូបថត រឿងនិទាន ប្រវត្តិសាស្ត្រ និងការពន្យល់ផ្នែកបច្ចេកទេស សៀវភៅស្តីពី "ការដាំអភិវឌ្ឍន៍ចំការកៅស៊ូគ្រួសារ" បានចូលរួមចំណែកការចាប់ផ្តើមឡើងវិញនៃវិស័យ "អ្នកដាំកៅស៊ូតូចតាច" ។ សៀវភៅនេះបានផ្តួចផ្តើមឡើងដោយអង្គការយកផ្លូវកៅស៊ូ តាមរយៈការផ្តល់ជំនួយប្រាក់ របស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ។